# ពិធីការសម្រាប់សាលារៀនកម្រិត K-12៖ ឧបសម្ព័ន្ធ T1

**កំណត់សម្គាល់៖ ឯកសារនេះត្រូវបានធ្វើបច្ចុប្បន្នកម្មជាញឹកញាប់។ សូមពិនិត្យមើលកាលបរិច្ឆេទនៅលើគេហទំព័រសម្រាប់កំណែប្រែថ្មីបំផុត។**

**បច្ចុប្បន្នភាពថ្មីៗ** (ការផ្លាស់ប្តូរត្រូវបានរំលេចដោយពណ៌លឿង)
**3/11/2022**

- ចាប់ពីថ្ងៃទី 12 ខែមីនា ឆ្នាំ 2022 ទៅ មានការណែនាំយ៉ាងម៉ឺងម៉ាត់ ប៉ុន្តែមិនមែនតម្រូវចាំបាច់នោះទេ ឱ្យពាក់ម៉ាស់ពេលនៅក្នុងអគារ។
- តាមការស្នើសុំ សាលារៀនត្រូវបានតម្រូវចាំបាច់ឱ្យផ្តល់ជូនម៉ាស់កម្រិតវេជ្ជសាស្ត្រនិងឧបករណ៍ជំនួយការដកដង្ហើមដែលបិទជិតល្អ ទៅដល់បុគ្គលិកសាលារៀនដែលធ្វើការនៅខាងក្នុងអគារនិងមានទំនាក់ទំនងឬការប៉ះពាល់ជាមួយនឹងអ្នកដទៃ សម្រាប់ការប្រើប្រាស់ដោយស្ម័គ្រចិត្ត។
- ការកែសម្រួលឡើងវិញចំពោះផ្នែកសិល្បៈសម្តែងដើម្បីរួមបញ្ចូលនូវការដកចេញតម្រូវការនៃការពាក់ម៉ាស់ពេលនៅខាងក្នុងអគារ ការរក្សាគម្លាតរាងកាយនិងការធ្វើតេស្ត ហើយនិងការចាត់ចំណាត់ថ្នាក់ឡើងវិញនៃវិធានការណ៍ទាំងនេះទៅជាការណែនាំយ៉ាងម៉ឺងម៉ាត់វិញ។
- ការដកចេញនូវឯកសារយោងចំពោះពិធីការនៃករណីកើនឡើងខ្លាំង ដែលឥឡូវនេះ ខោនធីគឺស្ថិតក្នុងស្ថានភាពក្រោយនៃការកើនឡើងខ្លាំង។

នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles (DPH) កំពុងអនុវត្តវិធីសាស្ត្រតាមដំណាក់កាល ដែលមានការគាំទ្រដោយវិទ្យាសាស្ត្រ និងជំនាញការសុខភាពសាធារណៈ ដើម្បីអនុញ្ញាតឱ្យសាលារៀនដែលបម្រើសេវាកម្មដល់សិស្សចាប់ពីកម្រិតមត្តេយ្យដែលអាចផ្ទេរថ្នាក់បាន ដល់ថ្នាក់ទី 12 បើកដំណើរការឡើងវិញដោយសុវត្ថិភាព។ បន្ថែមលើល័ក្ខខ័ណ្ឌទៅលើសាលារៀនដែលបានដាក់ចុះដោយមន្ត្រីសុខាភិបាលសាធារណៈរបស់រដ្ឋ និងនាយកដ្ឋានអប់រំនៃរដ្ឋ California សាលារៀនក៏ត្រូវតែគោរពតាមពិធីការស្តីពីសុវត្ថិភាពបុគ្គលិកនិងសិស្ស និងការគ្រប់គ្រងការឆ្លងជំងឺទាំងនេះផងដែរ។

**ចូរកត់សម្គាល់ថា៖** ឯកសារនេះអាចនឹងត្រូវបានធ្វើឱ្យថ្មីទៀត នៅពេលដែលមានព័ត៍មាន និងធនធានថ្មីៗ។ សូមចូលទៅកាន់គេហទំព័រ ph.lacounty.gov/Coronavirus ដើម្បីទទួលបានឯកសារនេះដែលមានព័ត៌មានថ្មី។

ឯកសារនេះ ចាប់ផ្តើមជាមួយការពិភាក្សាអំពីការផ្តល់ជូននាពេលបច្ចុប្បន្ន សម្រាប់ការអប់រំនៅក្នុងបរិវេណសាលារៀនក្នុងខោនធី Los Angeles (LAC) និងបន្តទៅព័ត៌មានអំពីវិធីសាស្ត្រសុវត្ថិភាពជាក់លាក់ សម្រាប់បរិស្ថានសាលារៀន។

បញ្ជីត្រួតពិនិត្យការបើកថ្នាក់កម្រិត TK-12 ឡើងវិញនេះ ផ្តល់ជូននូវវិធានការណ៍សុវត្ថិភាពនៅក្នុងប្រាំផ្នែក៖

(1) គោលការណ៍ និងការអនុវត្តនៅកន្លែងធ្វើការដើម្បីការពារសុខភាពបុគ្គលិក និងសិស្ស
(2) វិធានការណ៍បង្កើតគម្លាតតាមដែលអាចធ្វើទៅបាន
(3) វិធានការណ៍ដើម្បីលើកកម្ពស់ការគ្រប់គ្រងការឆ្លងជំងឺ
(4) ការទំនាក់ទំនងជាមួយបុគ្គលិក សិស្ស ក៏ដូចជាគ្រួសារសិស្ស និងសាធារណជន។
(5) វិធានការណ៍ដែលធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព

ចំណុចសំខាន់ៗទាំង 5 នេះមានវិធីសាស្ត្រជាច្រើនដែលសាលារៀនរបស់អ្នកអាចជ្រើសរើសអនុវត្តបាន ខណៈដែលទីតាំងស្ថាប័នរបស់អ្នករៀបចំផែនការ ដើម្បីផ្តល់នូវបរិយាកាសប្រកបដោយសុវត្ថិភាពសម្រាប់បុគ្គលិក សិស្ស និងភ្ញៀវទាំងអស់។ ទោះបីជាវិធានការណ៍បង្ការ និងការពារមួយចំនួន ជាតម្រូវចាំបាច់ នៅតាមសាលារៀនទាំងអស់នាពេលបច្ចុប្បន្ននេះ ហើយត្រូវបានចង្អុលបង្ហាញយ៉ាងច្បាស់នៅក្នុងពិធីការខាងក្រោមក៏ដោយ វិធានការណ៍ភាគច្រើនគឺអាចមានជម្រើស និងដោយស្ម័គ្រចិត្ត។ ទោះជាយ៉ាងណាក៏ដោយ វាជាចំណុចសមរម្យសម្រាប់ឱ្យសាលារៀនអនុវត្តវិធីសាស្ត្រច្រើនកម្រិត ដើម្បីកាត់បន្ថយជំងឺ COVID-19 នៅពេលបើកដំណើរការពេញលេញសាជាថ្មី ដើម្បីកំណត់ការចម្លងនៅតាមបរិវេណសាលារៀនផងដែរ។ វិធានការបន្ថែមដែលបានពិពណ៌នានៅក្នុង ឧបសម្ព័ន្ធ T2៖ ផែនការគ្រប់គ្រងការប៉ះពាល់មេរោគសម្រាប់សាលារៀនកម្រិត K-12 ថែមទាំង**ត្រូវតែ**អនុវត្ត និងមានប្រសិទ្ធិភាពចំពោះបុគ្គលិកនៅនឹងកន្លែងធ្វើការទាំងអស់។ ធនធានបន្ថែមទៀតសម្រាប់សាលារៀនកម្រិត TK-12 អាចរកបាននៅក្នុង សៀវភៅណែនាំនៃជំងឺ COVID-19 សម្រាប់សាលារៀនកម្រិត TK-12។

**ការណែនាំទូទៅនៃការបើកឱ្យដំណើរការឡើងវិញសម្រាប់សាលារៀនទាំងអស់**

**នៅពេលនេះ សាលារៀនទាំងអស់ត្រូវបានអនុញ្ញាតឱ្យបើកឡើងវិញសម្រាប់សិស្សទាំងអស់ ដែលកំពុងសិក្សាក្នុងកម្រិតថ្នាក់ TK-12 ទាំងឡាយ។**

**កំណត់សម្គាល់សម្រាប់កម្មវិធីថែទាំកុមារដែលមានទីតាំងស្ថិតនៅក្នុងសាលារៀន។** ភ្នាក់ងារវិស័យអប់រំតាមមូលដ្ឋាន (LEAs) និងសាលារៀនដែលមានផ្តល់សេវាកម្មថែទាំកុមារនៅក្នុងបរិវេណសាលារៀន គួរតែយោងទៅលើ សេចក្តីណែនាំសម្រាប់អ្នកផ្តល់សេវាកម្ម ECE របស់ DPH។

| **ការចាក់ថ្នាំបង្ការជំងឺ COVID-19 គឺជាប្រព័ន្ធការពារជួរមុខ** |
|---|
| ការសម្រេចបាននូវអត្រាចាក់ថ្នាំបង្ការខ្ពស់នៅក្នុងបរិវេណសាលារៀនរបស់អ្នក គឺជាមធ្យោបាយដំបូងនិងល្អបំផុតដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងនិងការចម្លងមេរោគនៅឯសាលារៀនរបស់អ្នក កាត់បន្ថយហានិភ័យយ៉ាងខ្លាំងនៃការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងការស្លាប់ចំពោះអ្នកដែលបានចាក់ថ្នាំបង្ការពេញលេញ និងផ្តល់នូវស្រទាប់ការពារបន្ថែមទៀតសម្រាប់អ្នកដែលមិនអាចទទួលការចាក់ថ្នាំបង្ការពេញលេញ មានប្រព័ន្ធភាពសុំាចុះខ្សោយ ឬក៏មានបញ្ហាសុខភាពមិនបង្ហាញមុខ។ សម្រាប់ហេតុផលនេះ បន្ថែមពីលើតម្រូវការនិងការណែនាំទាំងអស់ដែលបានសរសេរនៅក្នុងពិធីការនេះ សាលារៀនត្រូវបានជម្រុញឱ្យទទួលយកវិធីសាស្ត្រដែលធ្វើឱ្យមានលក្ខណៈធម្មតា លើកកម្ពស់ និងសម្រួលដល់ការចាក់ថ្នាក់បង្ការជំងឺ COVID-19 និងដូសជំរុញសម្រាប់បុគ្គលិក និងសិស្សដែលមានសិទ្ធិទាំងអស់នៅក្នុងបរិវេណសាលារៀនរបស់អ្នក។ សូមមើល សៀវភៅណែនាំអំពីការចាក់ថ្នាំបង្ការរបស់ LACDPH សម្រាប់សាលារៀន ដែលជាការណែនាំជាជំហានៗដោយមានគំរូអនុវត្តល្អបំផុត សម្រាប់ការរៀបចំសាលារៀនដើម្បីធ្វើទៅជាកន្លែងផ្តល់ការចាក់ថ្នាំបង្ការ។ ត្រូវដឹងផងដែរថា សេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាល ដែលបានចេញដោយរដ្ឋកាលីហ្វ័រញ៉ានៅថ្ងៃទី 11 ខែសីហា ឆ្នាំ 2021 តម្រូវឱ្យបុគ្គលិកសាលារៀនទាំងអស់បង្ហាញភស្តុតាងនៃការចាក់ថ្នាំបង្ការពេញលេញ ឬធ្វើតេស្តរកមេរោគយ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍។ រដ្ឋក៏បានប្រកាសផងដែរថា សិស្សនឹងតម្រូវចាំបាច់ឱ្យចាក់ថ្នាំបង្ការសម្រាប់ការសិក្សាដោយផ្ទាល់នៅពេលចាប់ផ្តើមត្រីមាស បន្ទាប់ពីទទួលបានការអនុម័តពេញលេញពីរដ្ឋបាលចំណីអាហារ និងឱសថ (FDA) ទាក់ទងនឹងថ្នាំបង្ការសម្រាប់កម្រិតថ្នាក់របស់ពួកគេ (ចន្លោះពីអាយុ 7 ទៅ 12 ឆ្នាំ និងថ្នាក់រៀនកម្រិត K-6)។ |

**បញ្ជីត្រួតពិនិត្យនៃការទប់ស្កាត់ជំងឺ COVID-19 នៅសាលារៀនកម្រិត TK ដល់ថ្នាក់ទី 12**

**ឈ្មោះស្ថាប័ន៖** ______________________________

**អាស័យដ្ឋាន៖** ______________________________

**កំណត់សម្គាល់៖** ពាក្យថា "អ្នកធ្វើការ" និង "បុគ្គលិក" ត្រូវបានប្រើប្រាស់នៅក្នុងពិធីការទាំងនេះ ដើម្បីសំដៅលើបុគ្គលដែលធ្វើការនៅក្នុងសាលារៀនក្នុងផ្នែកណាមួយដែលពាក់ព័ន្ធនឹងការបង្រៀន ការបង្ហាត់ ជំនួយសិស្ស ផ្តល់ការព្យាបាលដោយមិនប្រើប្រាស់ថ្នាំឬជំនួយផ្ទាល់ខ្លួនដល់សិស្សម្នាក់ៗ ការសម្អាតនិងថែទាំអគារ រដ្ឋបាល ឬសកម្មភាពផ្សេងៗទៀតដែលចាំបាច់ដើម្បីឱ្យសាលារៀនដំណើរការបាន។ "អ្នកធ្វើការ" ឬ "បុគ្គលិក" អាចរាប់បញ្ចូលបុគ្គលដែល៖ ទទួលប្រាក់ឈ្នួលដោយផ្ទាល់ពីប្រព័ន្ធសាលារៀនដែលពាក់ព័ន្ធ ទទួលប្រាក់ឈ្នួលពីស្ថាប័នដែលដើរតួជាអ្នកម៉ៅការជាមួយសាលារៀន ទទួលប្រាក់ឈ្នួលពីស្ថាប័នខាងក្រៅដែលសហការជាមួយសាលារៀនដើម្បីបម្រើសេវាកម្មដល់សិស្ស ទទួលប្រាក់ឈ្នួលពីភាគីទីបីដើម្បីផ្តល់សេវាកម្មដល់សិស្សម្នាក់ៗ ឬជាអ្នកស្ម័គ្រចិត្តដែលគ្មានប្រាក់ឈ្នួលហើយធ្វើការក្រោមការណែនាំរបស់សាលារៀនដើម្បីបំពេញមុខងារសំខាន់ៗ។ ពាក្យ "ឪពុកម្តាយ" ត្រូវបានប្រើប្រាស់នៅក្នុងពិធីការទាំងនេះដើម្បីសំដៅ លើបុគ្គលទាំងឡាយណាដែលដើរតួជាអ្នកផ្តល់ការថែទាំ ឬអាណាព្យាបាលសិស្ស។

## A. គោលការណ៍ និងការអនុវត្តនៅកន្លែងធ្វើការដើម្បីការពារបុគ្គលិក ("អ្នកធ្វើការ") និងសិស្ស (សូមគូសធីកគ្រប់ចំណុចដែលអនុវត្ត)

សាលារៀនត្រូវតែមានផែនការទប់ស្កាត់ ឆ្លើយតប និងគ្រប់គ្រងជំងឺ COVID-19 ដែលពិពណ៌នាអំពីវិធីសាស្ត្រដ៏ទូលំទូលាយរបស់សាលារៀនដើម្បីទប់ស្កាត់ និងគ្រប់គ្រងការរីករាលដាលនៃជំងឺ COVID-19 នៅក្នុងបរិវេណសាលារៀន។

ផែនការរួមមាន ប៉ុន្តែមិនមានត្រឹមចំណុចដូចខាងក្រោម៖

- ❑ ក្រុមការងារអនុវត្តច្បាប់សម្រាប់ជំងឺ COVID-19 ដែលត្រូវបានចាត់តាំង ហើយដែលនឹងទទួលខុសត្រូវលើការបង្កើត និងអនុវត្តពិធីការសុវត្ថិភាពជំងឺ COVID-19 ទាំងអស់ និងប្រាកដថាបុគ្គលិកនិងសិស្សទទួលបានការអប់រំ អំពីជំងឺ COVID-19។ សមាជិកម្នាក់នៃក្រុមការងារនេះ ត្រូវបានចាត់តាំងជាអ្នកទាក់ទងជាមួយ DPH ក្នុងករណីដែលមានការផ្ទុះឡើងនៃជំងឺនៅក្នុងបរិវេណសាលារៀន។
- ❑ ផែនការ ឬពិធីការមួយសម្រាប់ជំហានដែលនឹងត្រូវអនុវត្តភ្លាមៗបន្ទាប់ពីមានការជូនដំណឹងដោយបុគ្គលិកសាលារៀនថា សមាជិកណាម្នាក់នៃសហគមន៍សាលារៀន (មន្ត្រី បុគ្គលិក សិស្ស ឬភ្ញៀវ) ធ្វើតេស្តជំងឺ COVID-19 ទទួលលទ្ធផលថាវិជ្ជមាន។
- ❑ ផែនការនេះនិយាយអំពី៖
    - ការបំបែកករណីចេញពីសហគមន៍សាលារៀនភ្លាមៗ ដើម្បីឱ្យដាក់ខ្លួនឯងនៅដាច់ដោយឡែកនៅផ្ទះ ប្រសិនបើការជូនដំណឹងកើតឡើងខណៈដែលករណីស្ថិតនៅទីតាំងនោះ។ ផែនការត្រូវតែអនុញ្ញាតឱ្យមានការដាក់ខ្លួនករណីឱ្យនៅដាច់ដោយឡែកជាបណ្តោះអាសន្ននៅនឹងទីតាំងនោះ ប្រសិនបើចាំបាច់ត្រូវមានការរៀបចំសម្រាប់ឱ្យបុគ្គលនោះត្រឡប់ទៅផ្ទះរបស់ខ្លួនវិញ។
    - តារាងព័ត៌មានពិត ឬឯកសារព័ត៌មានផ្សេងៗទៀតដែលត្រូវប្រគល់ឱ្យករណី (ឬសមាជិកគ្រួសារដែលសមស្របប្រសិនបើករណីគឺជាកុមារ) នឹងរៀបរាប់អំពីបទប្បញ្ញត្តិគ្រប់គ្រងលើការដាក់ខ្លួនឯងឱ្យនៅដាច់ដោយឡែក និងតំណទៅកាន់គេហទំព័រដែលមានព័ត៌មានបន្ថែម។
- ❑ ផែនការ ឬពិធីការមួយដើម្បីចាប់ផ្តើម ផែនការគ្រប់គ្រងការប៉ះពាល់នៅសាលារៀន **ដែលស្របទៅតាមការណែនាំរបស់នាយកដ្ឋានសុខភាពសាធារណៈ (DPH)** ដោយគូសបញ្ជាក់ពីនីតិវិធីសម្រាប់៖
    - ការដាក់ករណីមួយ ឬច្រើនឱ្យនៅដាច់ដោយឡែក
    - ការកំណត់អត្តសញ្ញាណបុគ្គល ដែលបានប៉ះពាល់ជាមួយករណីនៅសាលារៀន
    - ការធ្វើចត្តាឡីស័ករបស់បុគ្គលិក និងសិស្សដែលបានប៉ះពាល់នឹងមេរោគ ដោយយោងតាមសេចក្តីណែនាំដែលបានពិពណ៌នានៅក្នុង ឧបសម្ព័ន្ធ T2៖ ផែនការគ្រប់គ្រងការប៉ះពាល់មេរោគសម្រាប់សាលារៀនកម្រិត K-12។
    - ការធានានៃការទទួលបានការធ្វើតេស្តសម្រាប់សិស្សដែលមានការប៉ះពាល់នឹងមេរោគ នៅក្នុងសាលារៀន ហើយដែលមិនបានចាក់ថ្នាំបង្ការពេញលេញទាំងអស់ និងបុគ្គលិកដែលមានការប៉ះពាល់នឹងមេរោគហើយដែលមិនបានទទួលចាក់ថ្នាំបង្ការពេញលេញទាំងអស់ ឬបានចាក់ថ្នាំបង្ការពេញលេញប៉ុន្តែហួសកាលកំណត់ចំពោះការចាក់ដូសជំរុញរបស់ពួកគេ។
    - ផ្តល់សេចក្តីជូនដំណឹងដល់ DPH អំពីករណីឆ្លងជំងឺ COVID-19 ច្បាស់លាស់ក្នុងចំណោមអ្នកធ្វើការ និងកុមារដែលបានស្ថិតនៅសាលារៀន នៅពេលណាមួយក្នុងអំឡុងពេល 14 ថ្ងៃមុនកាលបរិច្ឆេទចាប់ផ្តើមមានជំងឺ។ កាលបរិច្ឆេទចាប់ផ្តើមមានជំងឺ គឺជាកាលបរិច្ឆេទនៃការធ្វើតេស្តរកមេរោគ COVID-19 ឬកាលបរិច្ឆេទនៃការចាប់ផ្តើមចេញរោគសញ្ញារបស់អ្នកដែលមានជំងឺ គិតយកថ្ងៃណាដែលកើតឡើងមុន។ ការរាយការណ៍អំពីករណីនានាគួរតែត្រូវធ្វើក្នុងចន្លោះពេល 1 ថ្ងៃធ្វើការ បន្ទាប់ពីការជូនដំណឹងរបស់សាលារៀនអំពីករណីនេះ។ ការរាយការណ៍នេះអាចត្រូវបានបំពេញតាមបណ្តាញអ៊ិនធឺណិត ដោយការប្រើប្រាស់ពាក្យស្នើសុំប្រកបដោយសុវត្ថិភាពនៅលើគេហទំព័រ៖ http://www.redcap.link/lacdph.educationsector.covidreport ឬដោយទាញយក និងបំពេញ តារាងបញ្ជីករណី និងអ្នកដែលមានទំនាក់ទំនងនឹងជំងឺ COVID-19 សម្រាប់វិស័យអប់រំ ហើយផ្ញើវាទៅកាន់ ACDC-Education@ph.lacounty.gov។
- ❑ ផែនការមួយដើម្បីរាយការណ៍ករណីចង្កោមជាចង្កោម (3 ករណីឡើងទៅ ក្នុងអំឡុងពេល 14 ថ្ងៃ) ទៅកាន់នាយកដ្ឋានសុខភាពសាធារណៈជាបន្ទាន់។ នេះអាចត្រូវបានធ្វើដោយប្រើប្រាស់ជម្រើសរាយការណ៍ដូចគ្នាដែលបានរៀបរាប់ខាងលើ៖ (1) ការដាក់របាយការណ៍តាមបណ្តាញអ៊ិនធឺណិតនៅគេហទំព័រ http://www.redcap.link/lacdph.educationsector.covidreport ឬ (2) បំពេញឯកសារ តារាងបញ្ជីករណី និងអ្នកដែលមានទំនាក់ទំនងនឹងជំងឺ COVID-19 សម្រាប់វិស័យអប់រំ ហើយផ្ញើអ៊ីម៉ែលទៅ ACDC-Education@ph.lacounty.gov។ នាយកដ្ឋានសុខភាពសាធារណៈនឹងសហការជាមួយសាលារៀនដើម្បីកំណត់ថា តើក្រុមនេះអាចជាការផ្ទុះជំងឺដែលតម្រូវឱ្យមានការឆ្លើយតបនឹងការផ្ទុះជំងឺនៃសុខភាពសាធារណៈ ឬទេ។
- ❑ ផែនការត្រៀមបម្រុងសម្រាប់ការបិទទាំងស្រុង ឬដោយផ្នែកនៃប្រតិបត្តិការសាលារៀនដោយផ្ទាល់មុខ ប្រសិនបើចាំបាច់ ដោយផ្អែកលើការផ្ទុះឡើងនៃជំងឺនៅក្នុងសាលារៀន ឬសហគមន៍។

- ❑ ផែនការ ឬពិធីការមួយសម្រាប់ការបញ្ចូលការធ្វើតេស្តរកមេរោគ COVID-19 ទៅក្នុងប្រតិបត្តិការធម្មតារបស់សាលារៀន។
  - យ៉ាងហោចណាស់ ផែនការនេះគួរតែរៀបរាប់អំពីវិធីសាស្រ្តដើម្បីធានាការចូលធ្វើតេស្តសម្រាប់សិស្ស ឬបុគ្គលិកដែលមានរោគសញ្ញា ឬក៏បានស្គាល់ឬបានសង្ស័យថាមានការប៉ះពាល់ជាមួយបុគ្គលដែលផ្ទុកមេរោគ SARS-CoV-2។ ចូរកត់សម្គាល់ថា បទដ្ឋានបណ្តោះអាសន្នបន្ទាន់នៃការបង្ការជំងឺ COVID-19 (ETS) របស់ Cal/OSHA (CAL/OSHA ETS) តម្រូវឱ្យកន្លែងការងារផ្តល់ការធ្វើតេស្តដោយមិនគិតថ្លៃដល់បុគ្គលិក ក្នុងអំឡុងពេលម៉ោងដែលមានប្រាក់ពលកម្ម សម្រាប់៖
    - o បុគ្គលិកដែលមិនបានចាក់ថ្នាំបង្ការហើយមានរោគសញ្ញា ដោយមិនគិតថា តើមានការប៉ះពាល់ទៅនឹងមេរោគច្បាស់លាស់ ឬមិនមាននោះទេ។
    - o បុគ្គលិកដែលមិនបានចាក់ថ្នាំបង្ការ បន្ទាប់ពីការប៉ះពាល់ទៅនឹងមេរោគ។
    - o បុគ្គលិកដែលបានចាក់ថ្នាំបង្ការ បន្ទាប់ពីការប៉ះពាល់ទៅនឹងមេរោគ ប្រសិនបើពួកគេកើតមានរោគសញ្ញា។
    - o បុគ្គលិកដែលមិនបានចាក់ថ្នាំបង្ការនៅពេលមានការផ្ទុះឡើងនៃជំងឺ (ករណីបុគ្គលិកចំនួន 3 ឡើងទៅ)។
    - o បុគ្គលិកទាំងអស់នៅពេលមានការផ្ទុះឡើងនៃជំងឺធំ (ករណីបុគ្គលិកចំនួន 20 ឡើងទៅ)។
  - សាលារៀនត្រូវបានណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យរក្សាការធ្វើតេស្តគ្រប់គ្រាន់ដើម្បីធ្វើតេស្តសិស្សដែលមិនបានចាក់ថ្នាំបង្ការពេញលេញ និងបុគ្គលិកដែលស្ថានភាពនៃការចាក់ថ្នាំបង្ការរបស់ពួកគេមិនគ្រប់លក្ខណៈនិងមិនទាន់ពេលវេលា ឱ្យបានយ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍ក្នុងអំឡុងពេល 10 ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការប៉ះពាល់មេរោគចុងក្រោយរបស់ពួកគេ។ **សូមជូនដំណឹងដល់ DPH ជាបន្ទាន់ប្រសិនបើអ្នកមិនមានសមត្ថភាពធ្វើតេស្តគ្រប់គ្រាន់ដើម្បីបំពេញតាមតម្រូវការនេះទេ។** ប្រសិនបើមានធនធានអាចរៀបចំទៅបាន សាលារៀនគួរតែពង្រីកការធ្វើតេស្តដើម្បីបូករួមទាំងសិស្ស និងបុគ្គលិកដែលមានការប៉ះពាល់ទៅនឹងមេរោគ ហើយដែលពួកគេបានចាក់ថ្នាំបង្ការពេញលេញក៏ដោយ។
  - លើសពីនេះទៀត សាលារៀនប្រហែលជាអាចពិចារណាអំពីវិធីសាស្រ្តសម្រាប់ការធ្វើតេស្តតាមកាលកំណត់សម្រាប់បុគ្គលដែលមិនមានរោគសញ្ញា ហើយមិនមានការប៉ះពាល់ទៅនឹងមេរោគច្បាស់លាស់។ នាយកដ្ឋានសុខភាពសាធារណៈនៃរដ្ឋកាលីហ្វ័រញ៉ា (CDPH) មិនតម្រូវឱ្យមានការធ្វើតេស្តអ្នកដែលមិនមានរោគសញ្ញា តាមភាពញឹកញាប់ឬនីតិវិធីជាក់លាក់ណាមួយទេ នៅពេលនេះ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋបានផ្តល់ការគាំទ្រដល់ចង្វាក់នៃការធ្វើតេស្តជាក់លាក់ តាមរយៈការផ្គត់ផ្គង់ឧបករណ៍ធ្វើតេស្តបន្ថែម ការដឹកជញ្ជូន សមត្ថភាពមន្ទីរពិសោធន៍ បច្ចេកវិទ្យាសម្រាប់ការចុះឈ្មោះនិងការរាយការណ៍ ការបណ្តុះបណ្តាល និងជំនួយជាមួយនឹងសំណងធានារ៉ាប់រង។ សាលារៀនត្រូវបានណែនាំឱ្យចូលមើលព័ត៌មាន និងធនធានទាក់ទងនឹងការធ្វើតេស្តផ្តោតលើសាលារៀននៅ សុវត្ថិភាពសាលារៀនសម្រាប់គ្រប់ទីតាំងទាំងអស់។ នៅពេលដែលមានអត្រាការឆ្លងក្នុងសហគមន៍ខ្ពស់ ខោនធី LA ណែនាំឱ្យអនុវត្តការធ្វើតេស្តតាមការកំណត់នោះ បូករួមទាំងបុគ្គលដែលបានចាក់ថ្នាំបង្ការពេញលេញផងដែរ នៅទីណាដែលមានធនធានអាចរៀបចំទៅបាន។
  - គម្រោងត្រូវផ្តល់ការធានាថា លទ្ធផលតេស្តទាំងអស់នឹងត្រូវរាយការណ៍ទៅនាយកដ្ឋានសុខភាពសាធារណៈ។
  - ចូរកត់សម្គាល់ថា៖ ការធ្វើតេស្តត្រួតពិនិត្យមិនត្រូវបានណែនាំសម្រាប់បុគ្គលដែលបានជាសះស្បើយពីជំងឺ COVID-19 ដោយមានការបញ្ជាក់ពីមន្ទីរពិសោធន៍ ក្នុងអំឡុងពេល 90 ថ្ងៃកន្លងមកនេះ និងមិនមានរោគសញ្ញានោះទេ។
  - បានណែនាំបុគ្គលិកទាំងអស់កុំឱ្យមកធ្វើការ ប្រសិនបើមានជំងឺ។ មន្ត្រីនៅសាលារៀនបានផ្តល់ព័ត៌មានដល់បុគ្គលិកទាក់ទងនឹង អត្ថប្រយោជន៍សម្រាប់ការឈប់សម្រាកដែលបានឧបត្ថម្ភដោយកន្លែងការងារ ឬរដ្ឋាភិបាល។
- ❑ បុគ្គលិកដែលមានការប៉ះពាល់ទៅនឹងមេរោគ ឬសង្ស័យថាមានការប៉ះពាល់ជាមួយនឹងអ្នកដែលមានជំងឺ COVID-19 ត្រូវតែអនុវត្តតាមសេចក្តីណែនាំនៃការធ្វើចត្តាឡីស័កដូចមានចែងនៅក្នុង ឧបសម្ព័ន្ធ T2៖ ផែនការគ្រប់គ្រងការប៉ះពាល់មេរោគសម្រាប់សាលារៀនកម្រិត K-12។
- ❑ ការប្រើប្រាស់អគារសាលារៀនក្នុងគោលបំណងក្រៅពីការសិក្សា (ការប្រជុំឬព្រឹត្តិការណ៍សហគមន៍ ការចូលរួមគ្លីនិកនៅនឹងទីតាំងដោយបុគ្គលដែលមិនមែនជាសិស្សឬបុគ្គលិក ។ល។) ត្រូវបានអនុញ្ញាត។ ការប្រើប្រាស់បរិវេណអគារ

ខាងក្នុងសាលារៀនប្រឈមនឹងហានិភ័យកាន់តែច្រើននៃការចម្លងរោគដល់ខ្យល់នៅខាងក្នុងអគារ និងផ្ទៃផ្សេងៗ ហើយត្រូវមានការប្រុងប្រយ័ត្នដោយយកចិត្តទុកដាក់ ដើម្បីជៀសវាងការប៉ះពាល់ដែលមិនចាំបាច់ទៅលើមេរោគ សម្រាប់បុគ្គលិក និងសិស្សសាលារៀនជម្មតា។ ណែនាំឱ្យមានការលាងសម្អាតជាប្រចាំ សម្រាប់គ្រឿងបរិក្ខារនៅខាងក្នុងអគារ បន្ទាប់ពីមានការប្រើប្រាស់ដោយសមាជិកក្រុម ដែលមិនមែនជាសមាជិកនៃសាលារៀនហើយ។ អនុញ្ញាតឱ្យប្រើប្រាស់វាលកីឡាខាងក្រៅអគារដោយក្រុមកីឡាយុវជន ក្រុមសម្ព័ន្ធកីឡា ឬក្លឹបមិនទាក់ទងនឹងសាលារៀន ដរាបណាពួកគេយកចិត្តទុកដាក់ដើម្បីជៀសវាងការប៉ះពាល់នឹងមេរោគ ដែលមិនចាំបាច់សម្រាប់បុគ្គលិក និងសិស្សសាលារៀនជម្មតា។

- ការត្រួតពិនិត្យបុគ្គលិក ត្រូវបានណែនាំឱ្យអនុវត្ត មុនពេលអ្នកធ្វើការអាចចូលទៅទីកន្លែងនោះបាន។ ការត្រួតពិនិត្យគួរតែរាប់បញ្ចូល ការពិនិត្យទាក់ទងនឹងការក្អក ការដកដង្ហើមខ្លីៗ ការពិបាកដកដង្ហើម និងគ្រុនក្តៅឬគ្រុនរងា ហើយប្រសិនបើបច្ចុប្បន្ននេះ បុគ្គលិកកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឱ្យដាក់ខ្លួននៅដាច់ដោយឡែក ឬធ្វើចត្តាឡីស័ក។ ការត្រួតពិនិត្យទាំងនេះអាចធ្វើឡើងផ្ទាល់មុខនៅពេលមកដល់សាលារៀន ឬពីចម្ងាយមុនពេលមកដល់សាលារៀន ដោយប្រើប្រាស់កម្មវិធីឌីជីថល ឬវិធីសាស្ត្រផ្សេងទៀត។
- ចូរកត់សម្គាល់ថា CAL/OSHA ETS នាពេលបច្ចុប្បន្ននេះតម្រូវឱ្យកន្លែងការងារដកបុគ្គលិកដែលមានរោគសញ្ញានៃជំងឺ COVID-19 និង/ឬមិនបានចាក់ថ្នាំបង្ការពេញលេញ ហើយមានទំនាក់ទំនងឬការប៉ះពាល់ជិតស្និទ្ធនឹងបុគ្គលដែលមានមេរោគ ចេញពីកន្លែងធ្វើការ។ CAL/OSHA មិនបានចេញបញ្ជាចំពោះវិធីសាស្ត្រជាក់លាក់ណាមួយនៃការតាមដានបុគ្គលិកនោះទេ ប៉ុន្តែការអនុវត្តវិធីសាស្ត្រមួយចំនួនដូចដែលបានណែនាំ នឹងជួយក្នុងការអនុវត្តតាម ETS នាពេលបច្ចុប្បន្ននេះ។

❑ ការពាក់ម៉ាស់គឺជាការណែនាំយ៉ាងម៉ឺងម៉ាត់ ប៉ុន្តែមិនមែនតម្រូវចាំបាច់នោះទេ សម្រាប់បុគ្គលណាម្នាក់ដែលចូលក្នុងបរិវេណអគារសាលារៀន ឬយានជំនិះសាលារៀន (រថយន្តក្រុងរបស់សាលារៀន ក៏ដូចជាអគារសាលារៀន) ហើយដែលមានទំនាក់ទំនង ឬបានប៉ះពាល់ជាមួយអ្នកដទៃ (សិស្ស ឪពុកម្តាយ ឬបុគ្គលិកផ្សេងទៀត)។

- បុគ្គលិកដែលមានទំនាក់ទំនងឬបានប៉ះពាល់ជាមួយអ្នកដទៃត្រូវតែមានការផ្តល់ជូននូវម៉ាស់ ដែលមានកម្រិតការពារល្អណាស់ ដូចជាម៉ាស់កម្រិតវេជ្ជសាស្ត្រឬឧបករណ៍ជំនួយការដកដង្ហើម ដែលស្របទៅតាមការចង់បានរបស់បុគ្គលិក ដោយឥតគិតថ្លៃ។ មានការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យមានការពាក់ម៉ាស់គ្រប់ពេលវេលាក្នុងអំឡុងពេលធ្វើការ ពេលមានទំនាក់ទំនងឬប៉ះពាល់ជាមួយនឹងគ្នា ឬប្រហែលជាអាចនឹងមានទំនាក់ទំនងឬការប៉ះពាល់ជាមួយអ្នកដទៃ។ បុគ្គលិកដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្ររបស់ខ្លួនថា ពួកគេមិនចាំបាច់ពាក់ម៉ាស់ទេ ប៉ុន្តែមានបំណងចង់បន្ថែមកម្រិតការពារផ្ទាល់ខ្លួនរបស់ពួកគេឱ្យបានខ្ពស់បំផុតតាមដែលអាចធ្វើទៅបាននោះ អាចពិចារណាទៅលើជម្រើសដែលមិនមានការរឹតបន្តឹងដូចជា របាំងមុខដែលមានក្រណាត់រុំនៅលើគែមខាងក្រោម។ ក្រណាត់រុំដែលមានទ្រង់ទ្រាយពាក់បិទជិតនៅក្រោមចង្កាគឺជាការល្អបំផុត។
- តម្រូវការក្នុងការផ្តល់ម៉ាស់ដែលមានកម្រិតគុណភាពខ្ពស់ជាងមុនដល់បុគ្គលិកសាលារៀន៖ ដូចដែលបានកំណត់ខាងលើ ជាការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យបុគ្គលិកសាលារៀនទាំងឡាយ ពាក់ម៉ាស់កម្រិតសម្រាប់វះកាត់ (ក៏ត្រូវបានសម្តៅទៅលើម៉ាស់ដែលប្រើប្រាស់សម្រាប់នីតិវិធីវេជ្ជសាស្ត្រ) ឬឧបករណ៍ការពារផ្ទាល់ខ្លួន (PPE) ដែលមានកម្រិតខ្ពស់ជាងមុន (ឧទាហរណ៍ ម៉ាស់ដែលជាឧបករណ៍ជំនួយការដកដង្ហើមប្រភេទ KN95 ឬប្រភេទ N95) ពេលនៅខាងក្នុងអគារ។ សម្រាប់អ្នកដែលពាក់ម៉ាស់វះកាត់ ការពាក់ម៉ាស់ពីរជាន់ ដែលមានរបាំងមុខក្រណាត់ពីលើម៉ាស់វះកាត់ គឺត្រូវបានណែនាំឱ្យប្រើប្រាស់សម្រាប់ការការពារបន្ថែម។ កន្លែងការងារត្រូវបានតម្រូវចាំបាច់ឱ្យផ្តល់ជូនម៉ាស់កម្រិតវេជ្ជសាស្ត្រនិងឧបករណ៍ជំនួយការដកដង្ហើមដែលបិទជិតល្អ ដូចជាប្រភេទ N95 ប្រភេទ KN95 ឬប្រភេទ KF94 សម្រាប់ការប្រើប្រាស់ដោយស្ម័គ្រចិត្ត ហើយដោយមិនគិតថ្លៃពីបុគ្គលិកនៅសាលារៀនរបស់ពួកគេដែលធ្វើការនៅខាងក្នុងអគារ និងមានទំនាក់ទំនងឬការប៉ះពាល់ជាមួយនឹងអ្នកដទៃឡើយ។ សូមកត់សម្គាល់ថា CAL/OSHA តម្រូវឱ្យកន្លែងការងារផ្តល់ឧបករណ៍ជំនួយការដកដង្ហើមតាមការស្នើសុំចំពោះការប្រើប្រាស់ដោយស្ម័គ្រចិត្ត ដល់បុគ្គលិកដែលមិនបានទទួលចាក់ថ្នាំបង្ការ ហើយដែលកំពុងធ្វើការនៅខាងក្នុងអគារឬនៅក្នុងយានយន្តដែលមានមនុស្សច្រើនជាងម្នាក់ រួមជាមួយនឹងការណែនាំអំពីរបៀបធានាថាម៉ាស់បិទជិតដោយសមស្រប។
- មិនមានមនុស្សណាម្នាក់អាចត្រូវបានរារាំងពីការពាក់ម៉ាស់ ដែលជាល័ក្ខខ័ណ្ឌនៃការចូលរួមនៅក្នុងសកម្មភាព ឬការចូលទៅក្នុងទីតាំងរបស់សាលារៀន លុះត្រាតែការពាក់ម៉ាស់អាចនឹងបង្កគ្រោះថ្នាក់ផ្នែកសុវត្ថិភាព។
- មានការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យបុគ្គលិកពាក់ម៉ាស់គ្រប់ពេលវេលានៅខាងក្នុងអគារ លើកលែងតែនៅពេល

កំពុងធ្វើការតែម្នាក់ឯងនៅក្នុងការិយាល័យឯកជនដែលបិទទ្វារជិត នៅពេលដែលពួកគេជាមនុស្ស**តែ**ម្នាក់គត់ដែលមានវត្តមាននៅកន្លែងធ្វើការដែលធំទូលាយសម្រាប់បុគ្គលិកច្រើននាក់ ឬពេលកំពុងបរិភោគអាហារឬភេសជ្ជៈ។

- មានការណែនាំយ៉ាងម៉ឺងម៉ាត់ ប៉ុន្តែមិនមែនតម្រូវចាំបាច់នោះទេ ក្នុងការឱ្យសិស្សទាំងឡាយពាក់ម៉ាស់ដែលមានគុណភាពខ្ពស់ជាងមុនពេលនៅខាងក្នុងអគារ ដែលយ៉ាងហោចណាស់គឺមិនមែនជាម៉ាស់ក្រណាត់ ប៉ុន្តែជាម៉ាស់ដែលបានផលិតឡើងដោយវត្ថុធាតុដើមដែលមានច្រើនស្រទាប់ ហើយដែលមិនមែនជាសារធាតុដែលបានត្បាញ និងដោយមានខ្សែលួសពីលើផ្នែកច្រមុះ ហើយដែលបិទជិតល្អ។ (ម៉ាស់ក្រណាត់ដែលស្របតាមស្តង់ដាររបស់សង្គមអាមេរិកសម្រាប់ការធ្វើតេស្ត និងឧបករណ៍សម្ភារៈផ្សេងៗ (ASTM) ចំពោះប្រសិទ្ធិភាពនៃការច្រោះខ្ពស់ (ASTM F3502-កម្រិត 2) ក៏ស្របតាមការណែនាំសម្រាប់ម៉ាស់ដែលមានគុណភាពខ្ពស់ជាងមុនផងដែរ។ សូមមើលគេហទំព័រ ph.lacounty.gov/masks សម្រាប់ព័ត៌មានបន្ថែម។) មិនមានចំណុចណាមួយនៅក្នុងពិធីការនេះដែលតម្រូវឱ្យសាលារៀនផ្តល់ម៉ាស់ដែលមានគុណភាពខ្ពស់ជាងមុនដល់សិស្សានុសិស្សទូទៅទាំងអស់នោះទេ។ **ទោះជាយ៉ាងណាក៏ដោយ ការពាក់ម៉ាស់ដោយមានប្រភេទរបាំងមុខដែលសមស្របមួយចំនួនជាការណែនាំយ៉ាងម៉ឺងម៉ាត់ ខណៈពេលដែលនៅខាងក្នុងអគារ លើកលែងតែនៅពេលដែលកំពុងបរិភោគអាហារ ឬភេសជ្ជៈយ៉ាងសកម្មតែប៉ុណ្ណោះ។**
- សម្រាប់សេចក្តីណែនាំ និងព័ត៌មានថ្មីៗបំផុតរបស់ LACDPH ស្តីពីការពាក់ម៉ាស់ សូមយោងទៅលើគេហទំព័រ ម៉ាស់ការពារជំងឺ COVID-19។
- វិធីសាស្ត្រការពារផ្សេងទៀតអាចត្រូវបានអនុវត្ត ដើម្បីសម្រួលដល់សិស្សដែលស្ថិតនៅក្នុងផែនការនៃការអប់រំដែលមានលក្ខណៈបុគ្គល ឬផែនការ 504 (IEP) ឬក្នុងស្ថានភាពដែលការប្រើប្រាស់ម៉ាស់ជាឧបសគ្គដោយសារតែហេតុផលផ្នែកបង្ហាត់បង្រៀន ឬការលូតលាស់ផ្សេងៗ (ឧទាហរណ៍ ការប្រាស្រ័យទាក់ទង ឬជំនួយដល់កុមារតូចៗ ឬដល់មនុស្សដែលមានតម្រូវការពិសេស)។ សម្រាប់សិស្សដែលពេញចិត្តការការពារផ្ទាល់ខ្លួនដែលមានកម្រិតខ្ពស់ជាងមុន ប៉ុន្តែមិនអាចអត់ធន់នឹងការពាក់ម៉ាស់បានទេនោះ ពួកគេអាចពិចារណាពាក់របាំងមុខដែលមានក្រណាត់រុំនៅផ្នែកខាងក្រោម។
- សាលារៀនរដ្ឋទាំងអស់គួរតែដឹងអំពីតម្រូវការនៅក្នុងចំណុច AB 130 ដើម្បីផ្តល់ជូននូវកម្មវិធីសិក្សាឯករាជ្យសម្រាប់ឆ្នាំសិក្សា 2021-22។

- ❑ មានការណែនាំបុគ្គលិកដែលបន្តពាក់ម៉ាស់ ឱ្យសម្អាតឬប្តូរម៉ាស់របស់ពួកគេជារៀងរាល់ថ្ងៃ ហើយមានការបង្គាប់ទៅឪពុកម្តាយត្រូវឱ្យធានាថា កូនៗរបស់ពួកគេដែលបន្តពាក់ម៉ាស់មានយកជាមួយនូវម៉ាស់ស្អាតសម្រាប់ពាក់ជាច្រើន។
- ❑ បុគ្គលិកត្រូវបានហាមឃាត់មិនឱ្យបរិភោគអាហារឬភេសជ្ជៈ លើកលែងតែក្នុងអំឡុងពេលដែលអាចបង្កើនគម្លាតរាងកាយពីអ្នកដទៃ។
- ❑ គួរពិចារណាអំពីការបង្កើនគម្លាតរវាងបុគ្គលិកទាំងឡាយនៅក្នុងបន្ទប់ ឬនៅតាមទីតាំងណាមួយដែលត្រូវបានប្រើប្រាស់ដោយបុគ្គលិកសម្រាប់ការពិសាអាហារ និង/ឬការសម្រាក ជាពិសេសនៅពេលកន្លែងទំនេរនោះ ត្រូវបានប្រើប្រាស់រួមគ្នាដោយបុគ្គលិកដែលមិនបានចាក់ថ្នាំបង្ការពេញលេញ ឬមិនបានដឹងអំពីស្ថានភាពចាក់ថ្នាំបង្ការ។
- ❑ សាលារៀនគួរតែពិចារណាអនុវត្តវិធានការណ៍ដើម្បីជូនដំណឹងឱ្យបានច្បាស់លាស់ទៅកាន់បុគ្គលិក អ្នកម៉ៅការនៅនឹងទីតាំង អ្នកលក់ និងបុគ្គលិកដឹកជញ្ជូនទាំងអស់ ចំពោះការបង្គាប់អំពីការណែនាំយ៉ាងម៉ឺងម៉ាត់ និងការប្រើប្រាស់ដោយត្រឹមត្រូវទាក់ទងនឹងម៉ាស់ នៅពេលនៅជិតអ្នកដទៃខណៈនៅខាងក្នុងអគារ។
- ❑ បន្ទប់សម្រាក បន្ទប់ទឹក ថ្នាក់រៀន និងបរិវេណទូទៅផ្សេងទៀតដែលបុគ្គលិកត្រូវបានប្រើប្រាស់ឬចូលទៅ ត្រូវបានសម្អាតតាមភាពញឹកញាប់ដូចខាងក្រោម។ ការលាងសម្អាតជាប្រចាំត្រូវបានណែនាំឱ្យធ្វើ ដោយមិនត្រូវមានតិចជាងម្តងក្នុងមួយថ្ងៃ ក្នុងអំឡុងពេលប្រតិបត្តិការ ប៉ុន្តែអាចធ្វើញឹកញាប់ជាងនេះ។
    - បន្ទប់សម្រាក
    - បន្ទប់ទឹក
    - ថ្នាក់រៀន
    - បន្ទប់ពិសោធន៍
    - ការិយាល័យគិលានុបដ្ឋាយិកា
    - ទីកន្លែងប្រឹក្សាយោបល់ ឬជំនួយសិស្សផ្សេងទៀត

- ការិយាល័យខាងមុខ
- ការិយាល័យផ្សេងទៀត
- ផ្សេងទៀត (សាលប្រជុំ កន្លែងហាត់ប្រាណ បណ្ណាល័យ ប្រសិនបើប្រើប្រាស់) ________________________________

❑ ទីកន្លែងដែលមានការប៉ះពាល់ច្រើននៅក្នុងបន្ទប់សម្រាក ត្រូវបានណែនាំឱ្យសម្អាតយ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ។

❑ មានការណែនាំថា ត្រូវមានផ្តល់ទឹកអនាម័យលាងសម្អាតដៃ ដែលមានប្រសិទ្ធិភាពប្រឆាំងនឹងជំងឺ COVID-19 ដល់បុគ្គលិកទាំងអស់នៅក្នុង ឬក្បែរទីតាំងដូចខាងក្រោម (សូមគូសធីកគ្រប់ចំណុចដែលអនុវត្ត)៖

- ច្រកចូល ឬច្រកចេញអគារ__________
- ការិយាល័យកណ្តាល ________
- ច្រកឡើងជណ្តើរ ________
- ច្រកចូលជណ្តើរយន្ត (ប្រសិនបើមាន) __________
- ថ្នាក់រៀន ________
- បន្ទប់សម្រាករបស់មន្ត្រីសាលារៀន ________
- ការិយាល័យរបស់មន្ត្រីសាលារៀន៖ ________

❑ មានការណែនាំឱ្យបុគ្គលិកមានឱកាសលាងសម្អាតដៃរបស់ខ្លួនជាមួយសាប៊ូ និងទឹកឱ្យបានញឹកញាប់។

❑ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានចែកចាយទៅបុគ្គលិកទាំងអស់។

❑ ជម្រើសផ្សេង—ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត៖

______________________________________________________________________

## B. វិធានការណ៍ដើម្បីអនុញ្ញាតឱ្យរក្សាគម្លាតរាងកាយតាមការណែនាំ និងកាត់បន្ថយការជួបជុំមនុស្សច្រើនសម្រាប់បុគ្គលិក សិស្ស និងភ្ញៀវផ្សេងៗ (សូមគូសធីកគ្រប់ចំណុចដែលអនុវត្ត)

**កំណត់សម្គាល់**៖ នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី LA (LACDPH) ណែនាំថាវិធានការណ៍នានាដែលត្រូវអនុវត្តដើម្បីបង្កើនគម្លាតរាងកាយ ពេលដែលធ្វើដូច្នេះហើយ នឹងមិនរំខានដល់ការសិក្សាពេញម៉ោងរបស់សិស្សដែលបានចុះឈ្មោះទាំងអស់នោះទេ។ នេះមានសារៈសំខាន់ខ្លាំងណាស់ ក្នុងអំឡុងពេលដែលក្រុមសិស្សស្ថិតនៅខាងក្រៅថ្នាក់ (ឧទាហរណ៍ ការផ្លាស់ប្តូរវេននៅតាមច្រកផ្លូវដើរធំ) ដែលការបង្កើនការរក្សាគម្លាតរាងកាយជាជម្រើសល្អគួរតែធ្វើ។ សម្រាប់ស្ថានភាពពេលដែលការរក្សាគម្លាតរាងកាយមិនអាចធ្វើទៅបានទេ (ឧទាហរណ៍ ថ្នាក់រៀនដែលមានសិស្សពេញ) ការពាក់ម៉ាស់នៅតែជាការណែនាំយ៉ាងម៉ឺងម៉ាត់។

❑ ការពាក់ម៉ាស់ជាការណែនាំយ៉ាងម៉ឺងម៉ាត់ ប៉ុន្តែមិនមែនតម្រូវចាំបាច់នៅទេ ពេលនៅលើឡានក្រុងរបស់សាលារៀន។

❑ គួរពិចារណាអំពីការរក្សាវិធានការណ៍ដើម្បីលើកកម្ពស់ការរក្សាគម្លាតរាងកាយ រវាងសិស្សនៅលើរថយន្តក្រុងសាលារៀន ដោយសារតែមានសិស្សជាច្រើននៅតែមិនបានចាក់ថ្នាំបង្ការ។ ចំណុចទាំងនេះអាចរួមមាន (សូមគូសធីកគ្រប់ចំណុចដែលអនុវត្ត)៖

- កន្លែងអង្គុយមួយគឺសម្រាប់កុមារម្នាក់ នៅលើរថយន្តក្រុង។ __________
- ការប្រើប្រាស់ជួរឆ្លាស់គ្នា។ __________
- បើកបង្អួច ប្រសិនបើគុណភាពខ្យល់និងសុវត្ថិភាពអ្នកជិះ អាចអនុញ្ញាតបាន។ __________

❑ ពិចារណាលើការអនុវត្តវិធានការណ៍ដើម្បីកាត់បន្ថយការប្រមូលផ្តុំមនុស្សច្រើន នៅពេលដែលសិស្ស ឪពុកម្តាយ ឬភ្ញៀវចូល និងធ្វើដំណើរឆ្លងកាត់អគារសាលារៀន។ ចំណុចទាំងនេះអាចរួមមាន (សូមគូសធីកគ្រប់ចំណុចដែលអនុវត្ត)៖

- កាលវិភាគត្រូវបានកែសម្រួលដើម្បីជៀសវាងការប្រមូលផ្តុំគ្នានៅទីធ្លារួម ហើយអនុញ្ញាតឱ្យថ្នាក់រៀនតែមួយៗ ឬក្រុមតូចៗ ធ្វើដំណើរឆ្លងកាត់ទីធ្លារួមគ្នាបាន នៅពេលដែលអាចធ្វើទៅបាន (ដូចជាច្រកផ្លូវដើរធំ និងបន្ទប់ទឹក) នៅពេលវេលាណាមួយ។ ________
- បុគ្គលិកសាលារៀនត្រូវបានដាក់ឱ្យប្រចាំការនៅច្រកផ្លូវដើរក្នុងអគារ ដើម្បីលើកកម្ពស់នូវការរក្សាគម្លាត

រាងកាយ និងកាត់បន្ថយការដើរចុះឡើងនិងការប្រមូលផ្តុំគ្នា នៅពេលដែលសិស្សចូល និងដើរទៅកាន់ថ្នាក់រៀន។ ________

- វិធានការណ៍ខាងក្រោមអាចត្រូវបានអនុវត្តដើម្បីជៀសវាងការប្រមូលផ្តុំគ្នានៅតាមជណ្តើរ៖
  - ចាត់តាំងជណ្តើរឡើង និងចុះ ________________
  - ការសម្រាកបណ្តាក់គ្នា ចន្លោះពេលរៀន ________________
  - ការត្រួតពិនិត្យជណ្តើរដោយបុគ្គលិកសាលារៀន ________________
  - ផ្សេងទៀត៖ ________________________________________________

- [ ] គួរពិចារណាអនុវត្តវិធានការណ៍ដែលអនុញ្ញាតឱ្យមានការរក្សាគម្លាតរាងកាយនៅក្នុងថ្នាក់រៀន នៅពេលដែលអាចធ្វើទៅបាន ដោយមិនមានការរំខានដល់ប្រតិបត្តិការចាំបាច់នានា។ ចំណុចទាំងនេះអាចរួមមានទាំងវិធានការណ៍ដូចខាងក្រោម (សូមគូសធីកគ្រប់ចំណុចដែលអនុវត្ត)៖
  - គ្រឿងសង្ហារឹមក្នុងថ្នាក់រៀនត្រូវរៀបចំឡើងវិញ ដើម្បីបង្កើនគម្លាតរវាងសិស្សនិងសិស្ស ហើយរវាងសិស្សនិងគ្រូឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន។ ជាការអនុវត្តល្អបំផុតនោះ សូមជៀសវាងការប្រើប្រាស់ការរៀបចំកន្លែងអង្គុយជា "ទីតាំងផ្តុំគ្នា (pod)" នៅក្នុងថ្នាក់រៀននានា។ ទីណាដែលការរក្សាគម្លាតមិនអាចអនុវត្តទៅបាននោះ ចូរពិចារណាលើវិធានការណ៍សុវត្ថិភាពផ្សេងទៀតរួមមានការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យពាក់ម៉ាស់ពេលនៅខាងក្នុងអគារ។
  - ពិចារណាបង្កើន ឬធ្វើឱ្យប្រព័ន្ធខ្យល់ចេញចូលប្រសើរឡើង។
  - ពិចារណារក្សាការបង្កើនគម្លាតតាមដែលអាចធ្វើទៅបាននៅខាងក្នុងអគារ ពេលដែលសិស្ស ឬបុគ្គលិកមិនពាក់ម៉ាស់។
  - កន្លែងគេងថ្ងៃ ឬកន្លែងសម្រាកនៅក្នុងថ្នាក់រៀនសម្រាប់សិស្ស ត្រូវបង្កើនគម្លាតឆ្ងាយពីគ្នា និងដាក់ជើង និងក្បាលឆ្លាស់គ្នា។
  - ផ្សេងទៀត៖ ________________________________________________

- [ ] គួរពិចារណាផ្តល់ថ្នាក់កីឡានៅខាងក្រៅអគារ តាមដែលអាចធ្វើទៅបាន និងជ្រើសរើសសកម្មភាពដែលអនុញ្ញាតឱ្យមានការរក្សាគម្លាតរាងកាយ។ ក្នុងអំឡុងម៉ោងថ្នាក់កីឡាដែលធ្វើឡើងនៅខាងក្នុងអគារ មានការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យអ្នកដែលមានវត្តមានទាំងអស់ត្រូវពាក់ម៉ាស់ លើកលែងតែពេលកំពុងពិសាទឹក។

- [ ] គួរពិចារណាអនុវត្តគោលការណ៍សាលារៀនដែលជម្រុញឱ្យមានការរក្សាគម្លាតរាងកាយ ពេលនៅក្នុងបន្ទប់ដាក់សម្ភារៈ ឬប្តូរសំលៀកបំពាក់។ គោលការណ៍អាចរួមមាន៖
  - ផ្តល់សិទ្ធចូលប្រើប្រាស់បន្ទប់ដាក់សម្ភារៈឬប្តូរសំលៀកបំពាក់ នៅពេលដែលមានការគ្រប់គ្រងដោយបុគ្គលិកប៉ុណ្ណោះ។ បណ្តាក់ពេលចូលប្រើប្រាស់បន្ទប់ដាក់សម្ភារៈ ឬប្តូរសំលៀកបំពាក់។ ចូរពិចារណាអំពីការកំណត់ពេលវេលាសរុបសម្រាប់សិស្ស និងសិស្សដែលជាអត្តពលិក (អ្នកលេងកីឡាឱ្យសាលារៀន) គួរចំណាយនៅក្នុងបន្ទប់ដាក់សម្ភារៈ ឧទាហរណ៍ស្នើឱ្យសិស្សដែលជាអត្តពលិកងូតទឹកនៅផ្ទះរបស់ពួកគេបន្ទាប់ពីការហ្វឹកហាត់ និងការប្រកួតរួច។
  - បង្កើតជម្រើសផ្សេងទៀតសម្រាប់ការរក្សាទុកសំលៀកបំពាក់ សៀវភៅ និងវត្ថុផ្សេងទៀតរបស់សិស្ស។

- [ ] គួរពិចារណាអនុវត្តវិធានការណ៍ដើម្បីបង្កើនការរក្សាគម្លាតរាងកាយក្នុងពេលទទួលទានអាហារនៅសាលារៀន នៅពេលសិស្សដែលនៅខាងក្នុងអគារនិងមិនមានពាក់ម៉ាស់។ ចំណុចទាំងនេះអាចរួមមាន (សូមគូសធីកគ្រប់ចំណុចដែលអនុវត្ត)៖
  - ប្រសិនបើសិស្សតម្រង់ជួរយកម្ហូប មានប្រើប្រាស់បង់ស្អិតឬស្លាកសម្គាល់ផ្សេងទៀត ដើម្បីលើកកម្ពស់នូវការរក្សាគម្លាតរវាងសិស្សនិងសិស្ស។__________
  - ប្រសិនបើការបរិភោគអាហារធ្វើឡើងនៅក្នុងអាហារដ្ឋាន ម៉ោងបរិភោគអាហារត្រូវបានកំណត់ឱ្យបណ្តាក់គ្នា ដើម្បីកាត់បន្ថយចំនួនក្រុមផ្សេងៗនៅក្នុងអាហារដ្ឋានក្នុងពេលតែមួយ។__________
  - ប្រសិនបើការបរិភោគអាហារធ្វើឡើងនៅក្នុងអាហារដ្ឋាន គម្លាតរវាងតុ/កៅអី ត្រូវបានបង្កើនឡើងដើម្បីរក្សាចម្ងាយរវាងសិស្សនិងសិស្ស ក្នុងពេលបរិភោគ។

## C. វិធានការណ៍ដើម្បីធានាបាននូវការគ្រប់គ្រងការចម្លងមេរោគ (សូមគូសធីកគ្រប់ចំណុចដែលអនុវត្តសម្រាប់ទីកន្លែងផ្ទាល់)

- ❑ ការពិនិត្យរករោគសញ្ញាត្រូវបានណែនាំឱ្យធ្វើមុនពេលសិស្ស ភ្ញៀវ និងបុគ្គលិក ចូលក្នុងសាលារៀន។ ការត្រួតពិនិត្យតាមដានរួមមានការពិនិត្យមើលទាក់ទងនឹងរោគសញ្ញា ដែលដូចនឹងរោគសញ្ញានៃជំងឺ COVID-19 និងរោគសញ្ញាណាមួយដែលបុគ្គលអាចកំពុងកើតមាន។ ការពិនិត្យទាំងនេះអាចធ្វើឡើងពីចម្ងាយ [ឧទាហរណ៍ ដោយប្រើប្រាស់កម្មវិធីឌីជីថល (app)] ឬដោយផ្ទាល់មុខពេលមកដល់]។ ការត្រួតពិនិត្យសីតុណ្ហភាពដោយប្រើប្រាស់ប្រដាប់វាស់កម្តៅដែលមិនប៉ះស្បែកនៅពេលចូល អាចដាក់អនុវត្តបានជាផ្នែកនៃការពិនិត្យរកជំងឺ ជាពិសេសសម្រាប់ភ្ញៀវដែលមិនមែនជាផ្នែកមួយនៃប្រព័ន្ធពិនិត្យរកជំងឺរបស់ស្ថាប័ន ប្រសិនបើអាចធ្វើទៅបាន ។
  - សិស្ស បុគ្គលិក និងភ្ញៀវដែលពិនិត្យឃើញថាវិជ្ជមាននៅពេលចូល ឬដែលរាយការណ៍រោគសញ្ញានៅពេលណាមួយក្នុងម៉ោងនៅសាលារៀន នឹងគួរតែត្រូវបានរាយការណ៍ទៅក្រុមការងារអនុវត្តច្បាប់សម្រាប់ជំងឺ COVID-19 (សូមមើលផ្នែក A)។ ក្រុមអនុវត្តច្បាប់សម្រាប់ជំងឺ COVID-19 នឹងកំណត់ថាតើបុគ្គលនោះគួរតែត្រូវឱ្យចាកចេញពីកន្លែងនោះឬទេ តាមការណែនាំរបស់ DPH ស្តីពី វិធីសាស្រ្តសម្រេចចិត្តសម្រាប់ការតាមដានរោគសញ្ញា និងការប៉ះពាល់នឹងមេរោគ នៅតាមវិទ្យាស្ថានអប់រំនានា។ សិស្សដែលមានការពិនិត្យលទ្ធផលថាវិជ្ជមាន ត្រូវបានផ្តល់ម៉ាស់វះកាត់ លុះត្រាតែពួកគេកំពុងពាក់ម៉ាស់ដែលមានគុណភាពតាមការណែនាំនេះរួចហើយ និងត្រូវបាននាំទៅកាន់កន្លែងដាក់ឱ្យនៅដាច់ដោយឡែក ដែលត្រូវបានជ្រើសរើសជាមុន ហើយពួកគេអាចស្ថិតនៅទីនោះក្នុងពេលដែលក្រុមអនុវត្តច្បាប់សម្រេចចិត្ត អំពីការដកខ្លួនសិស្សចេញ និងរៀបចំគិតគូការវិលត្រឡប់ទៅផ្ទះវិញ តាមការបង្ហាញ។
- ❑ យោងទៅតាមវិធីសាស្រ្តសម្រេចចិត្តសម្រាប់ការតាមដានរោគសញ្ញានិងប៉ះពាល់នឹងមេរោគ របស់នាយកដ្ឋានសុខភាពសាធារណៈ (DPH Symptom and Exposure Screening Pathways) សិស្ស បុគ្គលិក និងភ្ញៀវដែលមានទំនាក់ទំនង ឬការប៉ះពាល់ជិតស្និទ្ធជាមួយនឹងបុគ្គលដែលបានពិនិត្យឃើញថាវិជ្ជមាន ចំពោះរោគសញ្ញាដែលដូចទៅនឹងរោគសញ្ញានៃជំងឺ COVID-19 នឹងត្រូវជូនដំណឹងអំពីការប៉ះពាល់ទៅនឹងជំងឺដែលអាចកើតមាននេះ។ សូមមើល ឧបសម្ព័ន្ធ T2៖ ផែនការគ្រប់គ្រងការប៉ះពាល់ទៅនឹងមេរោគសម្រាប់សាលារៀនកម្រិត K-12 សម្រាប់សេចក្តីណែនាំលម្អិត។ ការត្រួតពិនិត្យរកមេរោគសម្រាប់មនុស្សពេញវ័យ ក៏ដូចជាសិស្សថ្នាក់អនុវិទ្យាល័យ និងវិទ្យាល័យគួរតែរាប់បញ្ចូលទាំងសំណួរអំពីទំនាក់ទំនងឬការប៉ះពាល់ជិតស្និទ្ធជាមួយនឹងនរណាម្នាក់នៅផ្ទះ សាលារៀន ឬកន្លែងផ្សេងទៀតក្នុងអំឡុងពេល 10 ថ្ងៃកន្លងមក ដែលបុគ្គលនោះត្រូវបានធ្វើតេស្តទទួលលទ្ធផលថាវិជ្ជមានសម្រាប់ជំងឺ COVID-19។
  - បុគ្គលណាម្នាក់ដែលត្រូវបានត្រួតពិនិត្យចំពោះការប៉ះពាល់ទៅនឹងមេរោគនាពេលថ្មីៗ ហើយមានការរាយការណ៍ថាជាបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងអ្នកឆ្លងមេរោគនោះ គួរតែត្រូវបានចាត់ចែងតាមសេចក្តីណែនាំនៅក្នុង ឧបសម្ព័ន្ធ T2៖ ផែនការគ្រប់គ្រងការប៉ះពាល់ទៅនឹងមេរោគសម្រាប់សាលារៀនកម្រិត K-12។
- ❑ គួរពិចារណាអនុវត្តវិធានការណ៍ដើម្បីកំណត់ហានិភ័យនៃការឆ្លងមេរោគ ដោយសារការមកលេងនៃមនុស្សនានា ក្រៅពីបុគ្គលិកនិងសិស្ស។ ចំណុចទាំងនេះអាចរួមមាន (សូមគូសធីកគ្រប់ចំណុចដែលអនុវត្ត)៖
  - សាលារៀនគួរតែដាក់កំណត់ទៅលើភ្ញៀវ អ្នកស្ម័គ្រចិត្ត និងសកម្មភាពទាំងឡាយណា ដែលមានការចូលរួមពីក្រុម ឬអង្គភាពខាងក្រៅ ហើយដែលមានអ្នកដែលមិនបានចាក់ថ្នាំបង្ការពេញលេញ។
  - ភ្ញៀវគួរតែត្រូវបានចុះឈ្មោះនៅក្នុងកំណត់ហេតុភ្ញៀវ ដែលរួមមានឈ្មោះភ្ញៀវ លេខទូរស័ព្ទ និងអាស័យដ្ឋានអ៊ីម៉ែល ក្នុងករណីដែលត្រូវការព័ត៌មានទាំងនេះនាពេលអនាគត សម្រាប់គោលបំណងការតាមដានប្រវត្តិទំនាក់ទំនងមេរោគ។ ប្រសិនបើភ្ញៀវត្រូវតែមានមនុស្សម្នាក់ទៀតមកជាមួយ (ឧទាហរណ៍ សម្រាប់ជំនួយបកប្រែ ឬដោយសារភ្ញៀវគឺជាអនីតិជន ឬមានសិស្សជាក្មេងតូច) ព័ត៌មានទាំងនោះគួរតែត្រូវបានកត់ត្រានៅក្នុងកំណត់ត្រាភ្ញៀវផងដែរ។ ________
  - ចរាចរណ៍របស់ភ្ញៀវនៅក្នុងសាលារៀន យល់ល្អ ត្រូវបានដាក់កម្រិតត្រឹមទីកន្លែងដែលបានកំណត់ ដូចជាកន្លែងទទួលភ្ញៀវឬកន្លែងរង់ចាំ ការិយាល័យ បន្ទប់សន្និសីទឬបន្ទប់ប្រជុំ និងបន្ទប់ទឹកសាធារណៈទៅតាមកម្រិតដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយការទាក់ទង ដែលមិនចាំបាច់ ជាមួយក្រុមសិក្សាដែលមានស្ថេរភាពណាមួយឡើយ។ ________
  - មានការណែនាំយ៉ាងម៉ាត់ ប៉ុន្តែមិនមែនតម្រូវចាំបាច់នោះទេ សម្រាប់ឱ្យភ្ញៀវដែលមកដល់ទីតាំងសាលារៀនពាក់ម៉ាស់នៅគ្រប់ពេលវេលា ខណៈពេលនៅក្នុងបរិវេណសាលារៀន។ នេះអនុវត្តទៅលើមនុស្សពេញវ័យទាំង

អស់ និងកុមារដែលមានអាយុចាប់ពី 2 ឆ្នាំឡើងទៅ។ បុគ្គលដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្រថា ពួកគេមិនគួរពាក់ម៉ាស់នោះ គួរតែពាក់របាំងមុខដែលមានក្រណាត់រុំនៅលើគែមខាងក្រោម ខណៈណាដែលស្ថានភាពរបស់ពួកគេអាចធ្វើទៅបាន។ ពេញចិត្តឱ្យប្រើប្រាស់ក្រណាត់ដែលមានទ្រង់ទ្រាយពាក់បិទជិតនៅក្រោមចង្កាជាង។ ដើម្បីគាំទ្រសុវត្ថិភាពរបស់បុគ្គលិករបស់អ្នក និងភ្ញៀវផ្សេងទៀត ចូរពិចារណាផ្តល់ម៉ាស់ការពារដល់ភ្ញៀវដែលមកដល់ ហើយមិនយកម៉ាស់មកជាមួយ។ សម្រាប់សុវត្ថិភាពចំពោះភ្ញៀវក៏ដូចជាសិស្សានុសិស្សទាំងអស់នៅក្នុងសាលារៀននោះ មានការណែនាំបុ៉ន្តែមិនមែនតម្រូវចាំបាច់ទេ ដែលថាភ្ញៀវត្រូវពាក់ម៉ាស់ដែលមានគុណភាពខ្ពស់ជាងមុន ខណៈពេលកំពុងនៅក្នុងបរិវេណសាលារៀន ដូចជាម៉ាស់កម្រិតសម្រាប់វះកាត់ (ឬម៉ាស់ដែលប្រើប្រាស់សម្រាប់នីតិវិធីវេជ្ជសាស្ត្រ) ឬឧបករណ៍ការពារផ្ទាល់ខ្លួន (PPE) កម្រិតខ្ពស់ជាងមុន (ឧទាហរណ៍ ឧបករណ៍ជំនួយការដកដង្ហើមប្រភេទ KN95 ឬប្រភេទ N95)។

_________

- ❑ ការអនុវត្តវិធានការណ៍ដើម្បីលើកកម្ពស់ខ្យល់បក់ចេញចូលឱ្យល្អប្រសើរបំផុត នៅក្នុងសាលារៀនត្រូវបានណែនាំឱ្យអនុវត្តយ៉ាងម៉ឺងម៉ាត់។ ចំណុចទាំងនេះអាចរួមមាន (សូមគូសធីកគ្រប់ចំណុចដែលអនុវត្ត)៖
  - ការផ្លាស់ប្តូរការរៀនសូត្រ ការញ៉ាំអាហារ និងសកម្មភាពផ្សេងៗក្នុងថ្នាក់ ទៅកាន់ទីធ្លាខាងក្រៅអគារ ត្រូវធ្វើឱ្យបានកាន់តែច្រើនបំផុត នៅពេលណាដែលអាចធ្វើទៅបាន និងអាកាសធាតុអនុញ្ញាត។ _________
  - ប្រព័ន្ធម៉ាស៊ីនកម្តៅ ប្រព័ន្ធខ្យល់ និងម៉ាស៊ីនត្រជាក់រួមគ្នា (HVAC) នៅសាលារៀនមានសភាពល្អ និងដំណើរការធម្មតា។ មុនពេលបើកសាលារៀនឡើងវិញ គួរពិចារណាឱ្យប្រព័ន្ធម៉ាស៊ីនកម្តៅ ប្រព័ន្ធខ្យល់ និងម៉ាស៊ីនត្រជាក់រួមគ្នា មានការវាយតម្លៃដោយវិស្វករត្រឹមត្រូវ ដែលស្គាល់អំពីការណែនាំសម្រាប់ការបើកសាលារៀនឡើងវិញ (Guidance for Reopening School) ដែលត្រូវបានបង្កើតឡើងដោយសហគមន៍វិស្វករអាមេរិកសម្រាប់ប្រព័ន្ធកម្តៅ ប្រព័ន្ធក្លាសេ និងម៉ាស៊ីនត្រជាក់ (ASHRAE)។ _________
  - ប្រព័ន្ធម៉ាស៊ីនកម្តៅ ប្រព័ន្ធខ្យល់ និងម៉ាស៊ីនត្រជាក់រួមគ្នា ត្រូវបានកំណត់ឱ្យបង្កើនការផ្លាស់ប្តូរខ្យល់ក្នុង/ក្រៅអគារឱ្យបានកាន់តែច្រើនបំផុត លុះត្រាតែស្ថានភាពខាងក្រៅ (ទើបមានអគ្គីភ័យថ្មីៗ សីតុណ្ហភាពខាងក្រៅក្តៅខ្លាំង មានលម្អងផ្កាច្រើន ។ល។) ធ្វើឱ្យមិនសមស្រប។ _________
  - ម៉ាស៊ីនសម្អាតខ្យល់ចល័ត មានប្រសិទ្ធិភាពខ្ពស់ត្រូវបានតម្លើង ប្រសិនបើអាចធ្វើទៅបាន។ _________
  - ទ្វារ និងបង្អួចត្រូវបានបើកចំហក្នុងអំឡុងថ្ងៃសិក្សា ប្រសិនបើអាចធ្វើទៅបាន និងប្រសិនបើស្ថានភាពខាងក្រៅអំណោយផលដល់ការធ្វើបែបនេះ។ ត្រូវតែធ្វើតាមបទបញ្ជាមានស្រាប់ ទាក់ទងនឹងពេលមានអគ្គីភ័យដែលតម្រូវឱ្យបិទទ្វារដែលអាចទប់ភ្លើងបាន។_________
  - តម្រងខ្យល់ត្រូវបានតម្លើងឱ្យមានប្រសិទ្ធិភាពខ្ពស់ជាងធម្មតា (គួរប្រើប្រាស់កម្រិត MERV-13 ឬអត្រាខ្ពស់ជាងនេះ)។ _________
  - ដោយសារតែមានទំហំបន្ទប់ធំ និងមានសកម្មភាពដែលប្រឈមនឹងហានិភ័យខ្ពស់ដែលកំពុងកើតឡើងនៅលើទីលានហាត់កីឡា ការធ្វើឱ្យខ្យល់បក់ចេញចូលបានប្រសើរឡើងនៅក្នុងសាលហាត់កីឡា គឺជាមធ្យោបាយដ៏សំខាន់មួយដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងនិងការផ្ទុះឡើងនៃមេរោគ ដែលជាលទ្ធផលបង្កមកពីការប្រកួតកីឡាដែលប្រឈមនឹងហានិភ័យខ្ពស់។ ការប្រើប្រាស់កង្ហារតាមក្បួនត្រឹមត្រូវ ដើម្បីផ្លាស់ប្តូរខ្យល់នៅផ្ទាល់ដី អាចមានឥទ្ធិពលគួរឱ្យកត់សម្គាល់ក្នុងការកាត់បន្ថយហានិភ័យ។ សម្រាប់សេចក្តីណែនាំបន្ថែម សូមមើល [គំរូអនុវត្តល្អបំផុតសម្រាប់ប្រព័ន្ធខ្យល់បក់ចេញចូលនៅសាលហាត់ប្រាណ]។ _________
  - ផ្សេងទៀត៖________________________________________________________________
- ❑ មានការណែនាំឱ្យមានវិធានការណ៍ស្រាប់ដើម្បីលើកកម្ពស់ការសម្អាតទីធ្លា ផ្ទៃ និងវត្ថុផ្សេងៗក្នុងសាលារៀនទាំងមូល។ ចំណុចទាំងនេះអាចរួមមាន (សូមគូសធីកគ្រប់ចំណុចដែលអនុវត្ត)។
  - កាលវិភាគសម្អាតត្រូវបានបង្កើតឡើងដើម្បីជៀសវាងការប្រើប្រាស់ផលិតផលសម្អាតតិចពេក ឬច្រើនពេក។ _________
  - រថយន្តក្រុងត្រូវបានសម្អាតយ៉ាងជិតដល់ជារៀងរាល់ថ្ងៃ និងសម្លាប់មេរោគក្រោយពីដឹកជញ្ជូនបុគ្គលណាមួយដែលកំពុងចេញរោគសញ្ញានៃជំងឺ COVID-19។ អ្នកបើកបរមានបំពាក់ដោយក្រដាសជូតសម្លាប់មេរោគ និងស្រោមដៃប្រើប្រាស់ហើយអាចបោះចោលបាន ដើម្បីជំនួយដល់ការសម្លាប់មេរោគលើផ្ទៃតាមការចាំបាច់ ក្នុងអំឡុងពេលកំពុងធ្វើការ។
  - ប្រភពទឹកពិសាអាចដាក់សម្រាប់ប្រើប្រាស់វិញបាន។ ដើម្បីកាត់បន្ថយហានិភ័យនៃជំងឺរលាកសួតធ្ងន់ធ្ងរ

(Legionnaires) និងជំងឺដទៃទៀតដែលទាក់ទងនឹងទឹក សូមចាត់វិធានការណ៍ដើម្បីធានាថាគ្រប់ប្រព័ន្ធ និងទ្រង់ទ្រាយទឹកទាំងអស់ (ឧទាហរណ៍ ប្រភពទឹកពិសា ប្រភពទឹកតុបតែងលម្អ) មានសុវត្ថិភាពក្នុងការប្រើប្រាស់បន្ទាប់ពីមានការបិទកន្លែងយ៉ាងយូរកន្លងមក។ នេះរួមបញ្ចូលទាំងការបង្ហូរទឹកលាងឱ្យបានត្រឹមត្រូវ ហើយអាចចាំបាច់ត្រូវអនុវត្តតាមជំហាននៃការសម្អាតបន្ថែម (រួមទាំងការសម្លាប់មេរោគ)។ សូមមើលការណែនាំរបស់ CDC សម្រាប់ការបើកដំណើរការអគារឡើងវិញ បន្ទាប់ពីការបិទរយៈពេលយូរ ឬប្រតិបត្តិការថយចុះតាមគេហទំព័រ៖ https://www.cdc.gov/coronavirus/2019-ncov/php/building-water-system.html។

___________

- ផលិតផលសម្អាតដែលមានប្រសិទ្ធិភាពប្រឆាំងនឹងជំងឺ COVID-19 [មាននៅលើបញ្ជីបានអនុម័ត "N" ដោយទីភ្នាក់ងារការពារបរិស្ថាន (EPA)] ត្រូវបានប្រើប្រាស់ដោយយោងទៅតាមការណែនាំរបស់ផលិតផល។ នៅពេលដែលមិនមានសារធាតុសម្លាប់មេរោគដែលបានអនុម័តដោយ EPA សារធាតុសម្លាប់មេរោគជម្រើសផ្សេងទៀតអាចត្រូវបានប្រើប្រាស់ [ឧទាហរណ៍ ទឹកធ្វើឱ្យស (bleach) 1/3 ពែងដាក់ទៅក្នុងទឹក 1 ហ្គាឡុង (gallon) ឬក៏ជាល្បាយអាល់កុល 70%]។ កុំលាយទឹកធ្វើឱ្យស (bleach) ឬផលិតផលសម្អាតនិងសម្លាប់មេរោគផ្សេងទៀតចូលគ្នា - វាអាចបណ្តាលឱ្យមានផ្សែងពុលដែលមានគ្រោះថ្នាក់ខ្លាំងណាស់ក្នុងការដកដង្ហើម។

  __________

- បុគ្គលិកថែទាំ ឬបុគ្គលិកផ្សេងទៀតដែលទទួលខុសត្រូវចំពោះការសម្អាត និងការសម្លាប់មេរោគផ្ទៃ និងគ្រឿងបរិក្ខាក្នុងសាលារៀន បានទទួលការបណ្តុះបណ្តាលតាមការណែនាំរបស់ក្រុមហ៊ុនផលិត សេចក្តីតម្រូវការ Cal/OSHA សម្រាប់ការប្រើប្រាស់ដោយសុវត្ថិភាព និងដូចបានតម្រូវដោយច្បាប់ស្តីពីសាលារៀនមានសុខភាពល្អ (Healthy Schools Act) តាមការដែលអាចអនុវត្តទៅបាន។ __________
- បុគ្គលិកថែទាំ និងបុគ្គលិកផ្សេងទៀតដែលទទួលខុសត្រូវចំពោះការសម្អាតនិងការសម្លាប់មេរោគ ត្រូវបានបំពាក់ដោយឧបករណ៍ការពារផ្ទាល់ខ្លួន (PPE) ដូចជាស្រោមដៃ ការការពារភ្នែក ការការពារផ្លូវដង្ហើម និងឧបករណ៍ការពារសមស្របផ្សេងទៀតតាមតម្រូវការផលិតផល។ __________
- ផលិតផលសម្អាតទាំងអស់ត្រូវតែដាក់ឱ្យផុតពីដៃក្មេង និងទុកដាក់នៅក្នុងកន្លែងដែលមិនសូវមានការប៉ះពាល់។ __________
- ក្នុងអំឡុងពេលសម្អាតនិងសម្លាប់មេរោគ ត្រូវបង្កើនឱ្យមានខ្យល់បក់ចេញចូលបានច្រើនបំផុត ទៅតាមកម្រិតដែលអាចធ្វើទៅបាន។ ប្រសិនបើមានប្រើប្រាស់ម៉ាស៊ីនត្រជាក់ សូមដាក់កំណត់ឱ្យស្រូបយកខ្យល់បរិសុទ្ធពីខាងក្រៅ។ ផ្លាស់ប្តូរ និងត្រួតពិនិត្យតម្រងខ្យល់ និងប្រព័ន្ធតម្រងដើម្បីធានាបាននូវគុណភាពខ្យល់ល្អបំផុត។ __________
- ជំហានត្រូវបានអនុវត្តដើម្បីធានាថាប្រព័ន្ធទឹក និងកន្លែងបើកទឹកលាងដៃទាំងអស់ គឺមានសុវត្ថិភាពសម្រាប់ប្រើប្រាស់ បន្ទាប់ពីទីកន្លែងបានបិទទ្វារក្នុងរយៈពេលយូរ ដើម្បីកាត់បន្ថយហានិភ័យនៃជំងឺរលាកសួតធ្ងន់ធ្ងរ (Legionnaires) និងជំងឺផ្សេងទៀតដែលទាក់ទងនឹងទឹក។ ____________
- បន្ទប់ទឹក កន្លែងរង់ចាំ បន្ទប់សម្រាក ក៏ដូចជាកន្លែងអង្គុយលេង និងទីកន្លែងទូទៅផ្សេងទៀត ត្រូវបានសម្លាប់មេរោគ ដោយតាមភាពញឹកញាប់ដូចបានរាយតាមបញ្ជីខាងក្រោម។ ការលាងសម្អាតជាប្រចាំត្រូវបានណែនាំឱ្យធ្វើ មិនតិចជាងម្តងក្នុងមួយថ្ងៃ ក្នុងអំឡុងពេលប្រតិបត្តិការ ប៉ុន្តែអាចធ្វើញឹកញាប់ជាងនេះ។
  - បន្ទប់ទឹក៖ ____________
  - កន្លែងរង់ចាំ/កន្លែងចូល៖ ____________
  - បន្ទប់សម្រាករបស់គ្រូបង្រៀន/បុគ្គលិក៖____________
  - ថ្នាក់រៀន ____________
  - ទីកន្លែងបរិភោគនៅអាហារដ្ឋាន____________
  - កន្លែងរៀបចំម្ហូបអាហារនៅអាហារដ្ឋាន៖____________
  - ការិយាល័យខាងមុខ៖ ____________
  - ការិយាល័យផ្សេងទៀត៖____________
  - ទីកន្លែងផ្សេងទៀត៖ ____________

❑ វិធានការណ៍ត្រូវបានរៀបចំដើម្បីលើកកម្ពស់ការប្រើប្រាស់ម៉ាស់ដែលសមស្របដោយបុគ្គលិក សិស្ស និងភ្ញៀវទាំងអស់ពេលនៅខាងក្នុងអគារ ដើម្បីឱ្យស្របទៅតាមការណែនាំយ៉ាងម៉ឺងម៉ាត់នៅក្នុងសេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាល។

ចំណុចទាំងនេះត្រូវតែរួមមាន (សូមគូសធីកគ្រប់ចំណុចដែលអនុវត្ត)៖

- បុគ្គលិក ឪពុកម្តាយ និងសិស្សត្រូវបានផ្តល់ព័ត៌មានអំពីការណែនាំយ៉ាងមុឺងម៉ាត់ឱ្យពាក់ម៉ាស់ពេលនៅខាងក្នុងអគារ មុនពេលចាប់ផ្តើមឆ្នាំសិក្សា និងជាប្រចាំនៅក្នុងឆ្នាំសិក្សាទាំងមូល។ ________
- សិស្សទាំងអស់ដែលមានអាយុចាប់ពី 2 ឆ្នាំឡើងទៅត្រូវបានណែនាំយ៉ាងមុឺងម៉ាត់ឱ្យពាក់ម៉ាស់នៅគ្រប់ពេលវេលាខណៈពេលនៅខាងក្នុងបរិវេណសាលារៀន លើកលែងពេលកំពុងបរិភោគអាហារឬភេសជ្ជៈ ឬធ្វើសកម្មភាពផ្សេងទៀតដែលរារាំងដល់ការពាក់ម៉ាស់។ ________
- មានការណែនាំយ៉ាងមុឺងម៉ាត់ ប៉ុន្តែមិនមែនតម្រូវចាំបាច់នោះទេ ក្នុងការឱ្យសិស្សទាំងឡាយពាក់ម៉ាស់ដែលមានគុណភាពខ្ពស់ជាងមុន។ មានការណែនាំឱ្យពាក់ម៉ាស់ដែលបិទជិតល្អ ហើយមិនមែនជាម៉ាស់ក្រណាត់ ប៉ុន្តែជាម៉ាស់ដែលបានផលិតឡើងដោយវត្ថុធាតុដើមដែលមានច្រើនស្រទាប់ ហើយដែលមិនមែនជាសារធាតុដែលបានត្បាញ និងដោយមានខ្សែលួសពីលើផ្នែកច្រមុះ។ (ម៉ាស់ក្រណាត់ដែលស្របតាមស្តង់ដាររបស់សង្គមអាមេរិកសម្រាប់ការធ្វើតេស្ត និងឧបករណ៍សម្ភារៈផ្សេងៗ [ASTM] ចំពោះប្រសិទ្ធិភាពនៃការជ្រាបខ្ពស់ [ASTM F3502-កម្រិត 2] ត្រូវបានណែនាំឱ្យប្រើប្រាស់។ សូមមើលគេហទំព័រ [ph.lacounty.gov/masks](http://ph.lacounty.gov/masks) សម្រាប់ព័ត៌មានបន្ថែម។) មិនមានចំណុចណាមួយនៅក្នុងពិធីការនេះដែលតម្រូវឱ្យសាលារៀនផ្តល់ម៉ាស់ដែលមានគុណភាពខ្ពស់ជាងមុន ដល់សិស្សានុសិស្សទូទៅទាំងអស់នោះទេ។ **ទោះជាយ៉ាងណាក៏ដោយ ការពាក់ម៉ាស់ដោយមានប្រភេទរបាំងមុខដែលសមស្របមួយចំនួនត្រូវបានណែនាំយ៉ាងមុឺងម៉ាត់ខណៈពេលនៅខាងក្នុងអគារនៅតាមបរិវេណសាលារៀន** លើកលែងតែពេលកំពុងបរិភោគអាហារ ឬភេសជ្ជៈយ៉ាងសកម្មតែប៉ុណ្ណោះ។ វិធីសាស្ត្រការពារផ្សេងទៀតអាចត្រូវបានអនុវត្ត ដើម្បីសម្រួលដល់សិស្សដែលស្ថិតនៅក្នុងផែនការនៃការអប់រំដែលមានលក្ខណៈបុគ្គល (IEP) ឬផែនការ 504 ហើយសម្រាប់អ្នកដែលមានហេតុផលវេជ្ជសាស្ត្រដែលរារាំងពួកគេមិនឱ្យប្រើប្រាស់ ឬអត់ទ្រាំនឹងការពាក់ម៉ាស់បាន។ ពួកគេអាចពិចារណាជំនួសដោយការពាក់របាំងមុខដែលមានក្រណាត់រុំនៅផ្នែកខាងក្រោម ប្រសិនបើអាចទ្រាំពាក់វាបាន ហើយប្រសិនបើការប្រើប្រាស់ឧបករណ៍ការពារផ្ទាល់ខ្លួនគឺជាការចង់បានរបស់សិស្សឬឪពុកម្តាយ។
- មានការណែនាំថាព័ត៌មានត្រូវបានផ្តល់ជូនដល់បុគ្គលិក ឪពុកម្តាយ និងសិស្សទាក់ទងទៅនឹងការប្រើប្រាស់ម៉ាស់ឱ្យបានសមស្រប ដោយរាប់បញ្ចូលទាំងការចាំបាច់ក្នុងការសម្អាត ឬផ្លាស់ប្តូរម៉ាស់បន្ទាប់ពីការប្រើប្រាស់ក្នុងមួយថ្ងៃៗ។ ________
- មានការណែនាំថាស្លាកសញ្ញានៅច្រកចូលសាលារៀន នៅច្រកចូលការិយាល័យសាលារៀន និងទូទាំងអគារសាលារៀនទាំងមូល ពង្រឹងការណែនាំយ៉ាងមុឺងម៉ាត់នេះសម្រាប់ការប្រើប្រាស់ម៉ាស់ ត្រឹមត្រូវ។ ________
- ឪពុកម្តាយកុមារតូចៗ ដែលពេញចិត្តឱ្យកូនរបស់ពួកគេបន្តពាក់ម៉ាស់ជាងនោះ ត្រូវបានជម្រុញឱ្យផ្តល់ម៉ាស់ទីពីរដល់សាលារៀនជារៀងរាល់ថ្ងៃ ក្នុងករណីដែលម៉ាស់ដែលកុមារកំពុងពាក់នោះប្រឡាក់។ នេះនឹងអនុញ្ញាតឱ្យមានការផ្លាស់ប្តូរម៉ាស់នៅក្នុងថ្ងៃសិក្សា។ ________
- បុគ្គលិកដែលចូលរួមក្នុងសកម្មភាពផ្សេងៗ ដូចជាការផ្តល់ការព្យាបាលរាងកាយដោយមិនប្រើប្រាស់ថ្នាំ ឬជំនួយផ្ទាល់ខ្លួនដល់សិស្សម្នាក់ៗ ត្រូវបានបំពាក់ទៅដោយឧបករណ៍ការពារផ្ទាល់ខ្លួនសមស្រប (ស្រោមដៃ ម៉ាស់ អាវការពារ ។ល។)។ ________
- គ្រូបង្រៀន ឬបុគ្គលិកផ្សេងទៀតដែលពេញចិត្តចង់ពាក់ម៉ាស់ ប៉ុន្តែមានការព្រួយបារម្ភអំពីឧបសគ្គដែលអាចកើតមានទៅលើការបង្ហាត់បង្រៀនបញ្ចេញសម្លេង គួរតែពិចារណាចំពោះម៉ាស់ដែលមានផ្ទៃថ្លា ហើយដែលអាចមើលឃើញបបូរមាត់និងមាត់បាន។ ពួកគេក៏អាចពិចារណាជំនួសដោយការប្រើប្រាស់របាំងមុខដែលមានក្រណាត់រុំនៅផ្នែកខាងក្រោមផងដែរ។

❑ ការអនុវត្តវិធានការណ៍ដើម្បីលើកកម្ពស់ការលាងសម្អាតដៃឱ្យបានញឹកញាប់ដោយបុគ្គលិក សិស្ស និងភ្ញៀវ ត្រូវបានណែនាំឱ្យអនុវត្ត។ ចំណុចទាំងនេះអាចរួមមាន (សូមគូសធីកគ្រប់ចំណុចដែលអនុវត្ត)៖

- សិស្ស និងបុគ្គលិកមានឱកាសញឹកញាប់ដើម្បីលាងសម្អាតដៃរបស់ខ្លួនរយៈពេល 20 វិនាទីជាមួយសាប៊ូ ដោយដុសឱ្យបានសព្វល្អ និងប្រើប្រាស់ក្រដាស (ឬកន្សែងដែលប្រើប្រាស់តែម្តង) ដើម្បីជូតសម្ងួតដៃឱ្យបានហួតចត់។ ________
- សិស្សតូចៗត្រូវបានកំណត់កាលវិភាគជាប្រចាំសម្រាប់ការសម្រាកដើម្បីលាងសម្អាតដៃញឹកញាប់ ដោយរាប់បញ្ចូល ទាំងមុននិងក្រោយពេលបរិភោគ បន្ទាប់ពីប្រើប្រាស់បង្គន់ បន្ទាប់ពីលេងនៅខាងក្រៅ ក៏ដូចជាមុននិងក្រោយពីធ្វើសកម្មភាពជាក្រុមផ្សេងៗ។ ________
- បុគ្គលិកត្រូវបានណែនាំឱ្យធ្វើជាគំរូលាងសម្អាតដៃជាញឹកញាប់ ជាពិសេសនៅថ្នាក់សិស្សតូចៗ ដែលពេលវេលា

ប្រើប្រាស់បន្ទប់ទឹកគឺជាឱកាសដើម្បីពង្រឹងទម្លាប់ដែលមានសុខភាពល្អ និងត្រួតពិនិត្យការលាងសម្អាតដៃដែលសម
ស្រប។ ________

- ទឹកអនាម័យលាងសម្អាតដៃដែលមានជាតិអាល់កុលអេទីល (ethyl) [មានអេតាណុល (ethanol) យ៉ាងតិច 60%] គឺមានសម្រាប់សិស្ស និងបុគ្គលិកនៅតាមទីតាំងយុទ្ធសាស្ត្រក្នុងសាលារៀនទាំងមូល ដែលមិនមានកន្លែងបើកទឹកលាងសម្អាតដៃ ឬទឹកន្លែងលាងសម្អាតដៃចល័ត (នៅក្នុងឬជិតបន្ទប់រៀន បន្ទប់ដែលផ្តល់សេវាកម្មជំនួយ បន្ទប់តន្ត្រីនិងសិល្បៈ)។ ទឹកអនាម័យលាងសម្អាតដៃដែលមានជាតិអាល់កុលអេទីល គឺជាជម្រើសប្រសើរជាង និងគួរត្រូវប្រើប្រាស់នៅជុំវិញសាលារៀន។ ទឹកអនាម័យលាងសម្អាតដៃដែលមានអ៊ីសូប្រូពីលអាល់កុល (isopropyl) ជាសារធាតុផ្សំសកម្ម មិនត្រូវបានប្រើប្រាស់នៅតាមសាលារៀនឡើយ ព្រោះវាធ្វើឱ្យរោលស្បែក និងអាចជ្រាបចូលទៅក្នុងស្បែកបាន។ ________
- ការលេបទឹកអនាម័យលាងសម្អាតដៃដែលមានជាតិអាល់កុល អាចបណ្តាលឱ្យមានការពុលជាតិអាល់កុល។ ទឹកអនាម័យលាងសម្អាតដៃមិនមានដាក់នៅទីចំហ និងគួរត្រូវបានប្រើប្រាស់ដោយមានការគ្រប់គ្រងពីមនុស្សពេញវ័យសម្រាប់កុមារអាយុក្រោម 9 ឆ្នាំ។ មន្ត្រីសាលារៀន និងបុគ្គលិកត្រូវបានប្រាប់ឱ្យដឹងពីហានិភ័យនៃការលេបវា និងថាពួកគេគួរទូរស័ព្ទទៅផ្នែកគ្រប់គ្រងការពុល (Poison Control) តាមរយៈលេខ 1-800-222-1222 ប្រសិនបើមានហេតុផលដែលជឿថា សិស្សបានលេបទឹកអនាម័យលាងសម្អាតដៃ។ ________
- ទឹកអនាម័យលាងសម្អាតដៃ សាប៊ូនិងទឹក ក្រដាសជូត និងធុងសម្រាម គឺមានសម្រាប់សាធារណជននៅឬក្បែរច្រកចូលនៃទីកន្លែង ឬនៅកន្លែងទទួលភ្ញៀវ និងគ្រប់ទីកន្លែងផ្សេងទៀតនៅខាងក្នុងកន្លែងធ្វើការ ឬខាងក្រៅដែលមនុស្សមានការប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់។ ________

## ការពិចារណាពិសេសសម្រាប់ការសម្តែងសិល្បៈ

❑ **ថ្នាក់រៀនតន្ត្រី៖**

- មានការណែនាំយ៉ាងម៉ឺងម៉ាត់ដែលថាសកម្មភាពណាមួយដែលតម្រូវឱ្យអ្នកចូលរួមដោះម៉ាស់ចេញ អាចត្រូវបានធ្វើឡើងជាក្រុម ប្រសិនបើសកម្មភាពនេះត្រូវបានធ្វើឡើងនៅខាងក្រៅអគារ។
- ការលេងឧបករណ៍ខ្យល់នានា ដែលរៀបចំទីតាំងនៅខាងក្នុងអគារជាក្រុមត្រូវបានអនុញ្ញាត ដោយប្រកាន់ខ្ជាប់នូវវិធានការណ៍ដែលបានណែនាំយ៉ាងម៉ឺងម៉ាត់ ដូចខាងក្រោម៖
  - មានការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យអ្នកដែលលេងឧបករណ៍ខ្យល់នានា ពាក់របាំងមុខដែលបានកែសម្រួលត្រឹមត្រូវ ហើយដែលអនុញ្ញាតឱ្យមានការប៉ះដោយផ្ទាល់ជាមួយនឹងចំណុចប្រើប្រាស់មាត់នៃឧបករណ៍ នៅពេលណាដែលពួកគេកំពុងលេងឧបករណ៍នោះ។ ក្នុងអំឡុងពេលដែលសិស្សមិនកំពុងហ្វឹកហាត់ ឬសម្តែងយ៉ាងសកម្មទេ មានការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យពួកគេផ្លាស់ប្តូរទៅពាក់ម៉ាស់ដែលជិតពេញលេញវិញ។
  - មានការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យប្រើប្រាស់គម្របចំណុចបើកចំហឧបករណ៍ ក្នុងអំឡុងពេលលេងឧបករណ៍ខ្យល់នានា ។
  - មានការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យរក្សាគម្លាតរាងកាយឱ្យបានយ៉ាងហោចណាស់ 3 ហ្វីត រវាងបុគ្គលណាម្នាក់ដែលកំពុងលេងឧបករណ៍ខ្យល់ និងអ្នកចូលរួមដទៃទៀតទាំងអស់។
  - មានការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យសាលារៀនអនុវត្តការធ្វើតេស្តត្រួតពិនិត្យតាមទម្លាប់យ៉ាងហោចណាស់ជារៀងរាល់សប្តាហ៍ ដោយប្រើប្រាស់ការធ្វើតេស្តរកទម្រង់មេរោគ (PCR testing) ឬការធ្វើតេស្តរកសារធាតុដែលបញ្ចូលក្នុងខ្លួនដើម្បីបង្កើតភាពស៊ាំ (antigen testing) ចំពោះបុគ្គល**ទាំងអស់**ដែលចូលរួមក្នុងការហ្វឹកហាត់ ឬការសម្តែងជាក្រុមនៅខាងក្នុងអគារ ប្រសិនបើការពាក់ម៉ាស់ ការប្រើប្រាស់គម្របចំណុចបើកចំហឧបករណ៍ និងការរក្សាគម្លាតមិនកំពុងត្រូវបានអនុវត្តទេនោះ។
- នៅពេលកំពុងលេងឧបករណ៍ខ្យល់នៅខាងក្រៅអគារ សូមពិចារណាប្រើប្រាស់គម្របសម្រាប់ចំណុចបើកចំហនៃឧបករណ៍ខ្យល់នោះ ពាក់ម៉ាស់ដែលបានកែសម្រួលដែលអនុញ្ញាតឱ្យមានការប៉ះពាល់ដោយផ្ទាល់ជាមួយនឹងចំណុចប្រើប្រាស់មាត់នៃឧបករណ៍ និងថង់គ្របដែលបានរចនាឡើងយ៉ាងពិសេស ដោយមានដៃយួរសម្រាប់ឧបករណ៍ផ្លុំដូចជា ខ្លុយឬប៉ី ជាដើម ក៏ដូចជាការរក្សាគម្លាតរាងកាយ (6 ហ្វីតតាមការណែនាំ) រវាងបុគ្គលដែលលេងឧបករណ៍ខ្យល់ និងអ្នកចូលរួមផ្សេងទៀតដើម្បីកាត់បន្ថយការរីករាលដាលនៃដំណក់ទឹកតូចៗ និងភាគល្អិតតូចៗ។

- នៅពេលរៀបចំការបង្ហាត់បង្រៀន ការហាត់សម ឬការសម្តែងជាក្រុមនៅទីតាំងដែលមានការលាយគ្នាទាំងនៅខាងក្នុងនិងនៅខាងក្រៅអគារ មានការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យមានការធ្វើតេស្តត្រួតពិនិត្យមេរោគយ៉ាងហោចណាស់ជារៀងរាល់សប្តាហ៍ ដូចដែលបានពិពណ៌នាខាងលើសម្រាប់ទីតាំងនៅខាងក្នុងអគារ ប្រសិនបើការពាក់ម៉ាស់ ការប្រើប្រាស់គម្របចំណុចបើកចំហឧបករណ៍ និងការរក្សាគម្លាតមិនកំពុងត្រូវបានអនុវត្តទេនោះ។
- ចំពោះសកម្មភាពដែលប្រើប្រាស់កម្លាំងដកដង្ហើមចេញខ្លាំងហើយបង្កើតឱ្យមានដំណក់ទឹកតូចៗតាមរយៈផ្លូវដង្ហើមចេញមកច្រើន ដូចជាការច្រៀង មានការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យត្រូវបង្កើនគម្លាតរវាងគ្នានិងគ្នា និងចូលរួមក្នុងសកម្មភាពនៅខាងក្រៅអគារតែប៉ុណ្ណោះ។ ការធ្វើតេស្តតាមទម្លាប់ចំពោះសមាជិកទាំងអស់របស់ក្រុម យ៉ាងហោចណាស់ជារៀងរាល់សប្តាហ៍ ត្រូវបានណែនាំយ៉ាងម៉ឺងម៉ាត់ ប្រសិនបើអ្នកចម្រៀងកំពុងច្រៀងដោយមិនពាក់ម៉ាស់ និងដោយមិនមានការរក្សាគម្លាតរវាងកាយតាមការណែនាំ ពេលនៅក្នុងអគារ។
- តាមដែលអាចធ្វើទៅបាន ប្រើប្រាស់ទ្រនាប់បន្ទះឬប្រដាប់សម្រាប់ដាក់ផ្សេងទៀត ដែលជក់ទឹកហើយអាចបោះចោលបាន ដើម្បីទទួលយកសំណល់ទឹកមាត់ ដែលបានដក់ជាប់នឹងតម្រងទឹកមាត់ក្នុងឧបករណ៍ភ្លេងដែលប្រើប្រាស់ខ្យល់ហើយ។ ត្រូវបោះវាចោល ឬសម្អាតឱ្យបានត្រឹមត្រូវបន្ទាប់ពីប្រើប្រាស់រួច។

❑ **ថ្នាក់ល្ខោនៈ**

- មានការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យសិស្ស និងអ្នកបង្ហាត់នៅក្នុងថ្នាក់ល្ខោនពាក់ម៉ាស់គ្រប់ពេលវេលា ខណៈពេលដែលនៅខាងក្នុងអគារ។ មានការណែនាំឱ្យរក្សាគម្លាតរវាងកាយ ប្រសិនបើអ្នកចូលរួមកំពុងហាត់និយាយ (ឧទាហរណ៍ អ្នកដែលនៅក្នុងសិក្ខាសាលាល្ខោន)។
- ការធ្វើតេស្តតាមទម្លាប់យ៉ាងហោចណាស់ជារៀងរាល់សប្តាហ៍ ត្រូវបានណែនាំយ៉ាងម៉ឺងម៉ាត់សម្រាប់អ្នកចូលរួមទាំងអស់ ប្រសិនបើមិនមានការពាក់ម៉ាស់ ហើយមិនមានការរក្សាគម្លាតរវាងកាយ ខណៈពេលកំពុងអនុវត្ត ឬហាត់សមនៅខាងក្នុងអគារ។
- ពិចារណាធ្វើការហាត់សម និងការសម្តែងតាមអនឡាញ ឬនៅខាងក្រៅអគារជំនួសឱ្យនៅខាងក្នុងអគារ។ មានការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យពាក់ម៉ាស់គ្រប់ពេលវេលាចំពោះសកម្មភាពនៅខាងក្នុងអគារ។

❑ **ថ្នាក់រាំៈ**

- មានការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យសិស្សនិងអ្នកបង្ហាត់ ពាក់ម៉ាស់គ្រប់ពេល ខណៈពេលដែលនៅខាងក្នុងអគារ តាមដែលអាចអនុវត្តទៅបាន។
- ចំពោះសកម្មភាពដែលបង្កើតឱ្យមានដំណក់ទឹកតូចៗតាមរយៈផ្លូវដង្ហើមចេញមកច្រើន ដូចជាការខំប្រឹងខ្លាំង ណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យបង្កើនចម្ងាយរវាងគ្នានិងគ្នា និងត្រូវកំណត់រៀបចំសកម្មភាព ទាំងនេះឡើងនៅតែខាងក្រៅអគារប៉ុណ្ណោះ។
- ការធ្វើតេស្តពិនិត្យតាមទម្លាប់យ៉ាងហោចណាស់ជារៀងរាល់សប្តាហ៍ ត្រូវបានណែនាំយ៉ាងម៉ឺងម៉ាត់សម្រាប់អ្នកចូលរួមទាំងអស់ ប្រសិនបើមិនមានការពាក់ម៉ាស់ ហើយមិនមានការរក្សាគម្លាតរវាងកាយ ក្នុងអំឡុងពេលមានសកម្មភាពនៅខាងក្នុងអគារ។

❑ **ការថតតន្ត្រី**

- ការច្រៀងនៅក្នុងបន្ទប់សម្លេង/បន្ទប់ថតសម្លេង ត្រូវបានអនុញ្ញាតនៅពេលនេះ និងការពាក់ម៉ាស់គ្រប់ពេលវេលាត្រូវបានណែនាំយ៉ាងម៉ឺងម៉ាត់។ មានការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យបង្កើនគម្លាតរវាងអ្នកចំរៀង និងមនុស្សដទៃទៀតទាំងអស់នៅក្នុងបន្ទប់ ជាពិសេសប្រសិនបើអ្នកច្រៀងមិនពាក់ម៉ាស់ ដោយសារតែចំនួននៃដំណក់ទឹកតូចៗតាមផ្លូវដង្ហើមដ៏ច្រើនត្រូវបានបញ្ចេញចូលទៅក្នុងបរិវេណតូចមួយនៅខាងក្នុងអគារ។
- ការលេងឧបករណ៍ខ្យល់នៅក្នុងបន្ទប់សំសម្លេងជាមួយអ្នកដទៃដែលមាននៅក្នុងនោះដែរ ត្រូវបានអនុញ្ញាត សូមពិនិត្យផ្នែកខាងលើទាក់ទងនឹងថ្នាក់រៀនតន្ត្រី សម្រាប់ការណែនាំផ្សេងៗស្តីពីវិធីកែលម្អសុវត្ថិភាព និងកាត់បន្ថយហានិភ័យនៅពេលមានការលេងឧបករណ៍ខ្យល់។
- តន្ត្រីដែលប្រើប្រាស់ឧបករណ៍ជាក្រុមផ្សេងទៀត អាចថតបានដោយប្រើប្រាស់បន្ទប់សម្លេង ប៉ុន្តែមានការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យរក្សាគម្លាតរវាងកាយយ៉ាងហោចណាស់ 3 ហ្វីតរវាងតន្ត្រីករទាំងអស់គ្រប់ពេលវេលា ហើយមានការណែនាំយ៉ាងម៉ឺងម៉ាត់ ឱ្យពាក់ម៉ាស់។
- ការធ្វើតេស្តតាមទម្លាប់យ៉ាងហោចណាស់ជារៀងរាល់សប្តាហ៍ ត្រូវបានណែនាំយ៉ាងម៉ឺងម៉ាត់សម្រាប់សមាជិកទាំងអស់នៃក្រុមដែលប្រើប្រាស់បន្ទប់ថតសម្លេងរួមគ្នា ប្រសិនបើមនុស្សទាំងឡាយមិនពាក់ម៉ាស់ ហើយមិន

មានការប្រកាន់ខ្ជាប់ការរក្សាគម្លាតរាងកាយ។

- មុនពេលតន្ត្រីករ ឬក្រុមតន្ត្រីករផ្សេងប្រើប្រាស់បន្ទប់ គួរតែមើលថាបន្ទប់មានខ្យល់ចេញចូលបានល្អឬទេ (ពិចារណាប្រើប្រាស់ឧបករណ៍បន្សុទ្ធខ្យល់) ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរខ្យល់ឱ្យបានពេញលេញ និងគួរតែត្រូវសម្អាតឧបករណ៍ប្រើប្រាស់រួមគ្នា (ឧទាហរណ៍ មីក្រូ) ឱ្យមានអនាម័យ។

❑ **ការសម្តែង**

- ការសម្តែងណាក៏ដោយគួរតែអនុវត្តតាម សេចក្តីណែនាំនៃការអនុវត្តល្អបំផុតសម្រាប់ព្រឹត្តិការណ៍តូចៗ ដើម្បីកាត់បន្ថយហានិភ័យនៃការរីករាលដាលនៃជំងឺ COVID-19 លើកលែងតែការសម្តែង ឬព្រឹត្តិការណ៍របស់អ្នកគឺជាព្រឹត្តិការណ៍ធំៗបំផុតមួយ (ត្រូវបានកំណត់ថាមានអ្នកចូលរួមច្រើនជាង 1,000 នាក់នៅក្នុងទីតាំងកម្មវិធីដែលនៅខាងក្នុងអគារ ឬច្រើនជាង 10,000 នាក់នៅខាងក្រៅអគារ) នោះអ្នកគួរតែអនុវត្តតាម សេចក្តីណែនាំសម្រាប់ព្រឹត្តិការណ៍ធំៗបំផុត។
  - សម្រាប់ការសម្តែងទាំងអស់នៅក្នុងផលិតកម្មដែលបានឧបត្ថម្ភដោយសាលារៀនកម្រិត TK-12 ការពាក់ម៉ាស់ពេលនៅបរិវេណខាងក្នុងអគារ ដោយមនុស្សដែលមានវត្តមានទាំងអស់ ទាំងអ្នកទស្សនា និងអ្នកសម្តែង គឺត្រូវបានណែនាំយ៉ាងម៉ឺងម៉ាត់។ ចំពោះការសម្តែងដែលការពាក់ម៉ាស់មិនអាចធ្វើទៅបានទេនោះ មានការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យអ្នកសម្តែង និងក្រុមរៀបចំឆាកដែលមានទំនាក់ទំនងឬការប៉ះពាល់ជិតស្និទ្ធជាមួយនឹងអ្នកសម្តែង ត្រូវធ្វើតេស្តយ៉ាងហោចណាស់ជារៀងរាល់សប្តាហ៍ ដោយចាប់ផ្តើមមិនលើសពី 72 ម៉ោង មុនពេលចូលរួមការជួបជុំក្រុមផលិតកម្មលើកដំបូង និងបន្តរហូតដល់ចុងបញ្ចប់នៃកាលវិភាគការសម្តែង។

## D. វិធានការណ៍សម្រាប់ការទាក់ទងទៅនឹងសហគមន៍សាលារៀន និងសាធារណជន

❑ ព័ត៌មានគួរត្រូវបានផ្ញើទៅកាន់ឪពុកម្តាយនិងសិស្ស មុនពេលសាលារៀនចាប់ផ្តើម ពាក់ព័ន្ធនឹងគោលការណ៍សាលារៀនដែលទាក់ទងនឹង (សូមគូសធីកគ្រប់ចំណុចដែលអនុវត្ត)៖

- គោលការណ៍ដាក់ខ្លួនឱ្យនៅដាច់ដោយឡែក និងការធ្វើចត្តាឡីស័ក នៅពេលដែលគោលការណ៍ទាំងនេះអនុវត្តលើសិស្សដែលមានរោគសញ្ញា ឬអាចនឹងបានប៉ះពាល់ទៅនឹងមេរោគ COVID-19 ___________
- ជម្រើសសម្រាប់ការធ្វើតេស្តជំងឺ COVID-19 ប្រសិនបើសិស្ស ឬសមាជិកគ្រួសារមានរោគសញ្ញា ឬបានប៉ះពាល់ទៅនឹងមេរោគ COVID-19 ________
- អ្នកដែលត្រូវទាក់ទងនៅសាលារៀន ប្រសិនបើសិស្សមានរោគសញ្ញា ឬអាចនឹងត្រូវបានប៉ះពាល់ទៅនឹងមេរោគ៖ ______________________________________________
- របៀបធ្វើការពិនិត្យរោគសញ្ញាមុនពេលសិស្សចេញពីផ្ទះ៖ _________
- ការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យពាក់ម៉ាស់ពេលនៅខាងក្នុងអគារ ________
- សារៈសំខាន់នៃការអនុវត្តគោលការណ៍ ក្នុងការរក្សាគម្លាតរាងកាយណាមួយ និងគ្រប់គ្រងការឆ្លងជំងឺរបស់សិស្សនៅតាមទីតាំង ________
- ការផ្លាស់ប្តូរនៅក្នុងកម្មវិធីសិក្សា និងសកម្មភាពក្រៅកម្មវិធីសិក្សា ដើម្បីបញ្ចៀសហានិភ័យ __________
- គោលការណ៍សាលារៀនទាក់ទងនឹងការមកកាន់សាលារៀនដោយឪពុកម្តាយ និងការប្រឹក្សាយោបល់អំពីការទាក់ទងសាលារៀនពីចម្ងាយ ___________
- សារៈសំខាន់នៃការផ្តល់ព័ត៌មានទំនាក់ទំនងក្នុងករណីបន្ទាន់ដែលថ្មីបំផុតដល់សាលារៀន រួមទាំងជម្រើសច្រើនបែបដើម្បីទាក់ទងឪពុកម្តាយ ________
- ផ្សេងទៀត៖ ______________________________________________

❑ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានបិទផ្សាយនៅគ្រប់ច្រកចូលសាធារណៈទៅសាលារៀន ហើយបង្ហោះក្នុងទំព័រមុខសម្រាប់សាធារណៈនៅតាមគេហទំព័រសាលារៀន ឬតំបន់។

❑ ចូរពិចារណាបិទផ្សាយស្លាកសញ្ញានៅទូទាំងសាលារៀនទាំងមូលដែលរំលឹកបុគ្គលិក និងសិស្ស អំពីគោលការណ៍ទាក់ទងនឹងការណែនាំយ៉ាងម៉ឺងម៉ាត់សម្រាប់ការប្រើប្រាស់ម៉ាស់ពេលនៅខាងក្នុងអគារ និងសារៈសំខាន់នៃការលាងសម្អាតដៃ។

❑ ស្លាកសញ្ញាត្រូវបានបិទផ្សាយនៅច្រកចូលសាធារណៈនីមួយៗរបស់សាលារៀន ដែលរំលឹកដល់ភ្ញៀវថា ពួកគេមិនគួរ

ចូលក្នុងទីកន្លែងឡើយ ប្រសិនបើពួកគេមានរោគសញ្ញានៃជំងឺ COVID-19។

- ❑ សាលារៀនបានបង្កើត និងផ្សព្វផ្សាយផែនការទំនាក់ទំនងក្នុងករណីចាំបាច់ត្រូវបិទទាំងស្រុង ឬដោយផ្អែកលើករណីជំងឺ COVID-19 ជាចង្កោមដែលអាចកើតឡើង។
- ❑ បណ្តាញអនឡាញនៃសាលារៀន (គេហទំព័រ បណ្តាញសង្គម ។ល។) ផ្តល់ព័ត៌មានច្បាស់លាស់អំពីម៉ោងធ្វើការ គោលការណ៍មកកាន់សាលារៀន ការផ្លាស់ប្តូរកម្មវិធីសិក្សានិងសកម្មភាពក្រៅកម្មវិធីសិក្សា និងការតម្រូវឱ្យប្រើប្រាស់ម៉ាស់ ការរក្សាគម្លាតរាងកាយ និងការលាងសម្អាតដៃ។
- ❑ បណ្តាញអនឡាញណែនាំសិស្ស ឪពុកម្តាយ និងគ្រូបង្រៀន អំពីរបៀបទាក់ទងសាលារៀនក្នុងករណីដែលមានការឆ្លងជំងឺ ឬការប៉ះពាល់ទៅនឹងមេរោគ។

## E. វិធានការណ៍ដែលធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព

- ❑ គម្រោងសម្រាប់ការធ្វើផែនការអប់រំលក្ខណៈបុគ្គល (IEPs) និងផែនការ 504 របស់សិស្សដែលមានតម្រូវការពិសេស ឱ្យថ្មីទៀត ត្រូវបានបង្កើតឡើងដើម្បីធានាបានថា ការអប់រំអាចបន្តទៅបានដោយមិនប្រឈមនឹងហានិភ័យហួសហេតុដល់សិស្ស។
  - ផែនការនេះរាប់បញ្ចូលវិធីសាស្ត្រសម្រាប់ការទាក់ទងយ៉ាងសកម្មជាមុនជាមួយឪពុកម្តាយនៅដើមឆ្នាំសិក្សា ដើម្បីធានាថាបញ្ហាទាក់ទងនឹងការអប់រំនិងសុវត្ថិភាពកុមារកំពុងត្រូវបានដោះស្រាយ។
  - ការកែប្រែទៅលើផែនការ IEPs និងផែនការ 504 អាចទាក់ទងនឹងការសិក្សាពីចម្ងាយ ការកែប្រែទៅលើបន្ទប់រៀនដើម្បីសម្រួលដល់តម្រូវការសិស្ស វត្តមាននៅសាលារៀននៅក្នុងតំបន់ដាច់ដោយឡែកដែលមានសិស្សតិច ឬវិធីកូនកាត់ (hybrid) ដោយរួមបញ្ចូលការសិក្សានៅក្នុងថ្នាក់ និងការសិក្សាពីចម្ងាយ។
  - ជំហានដែលបានអនុវត្តដើម្បីកែប្រែផែនការ IEPs និងផែនការ 504 ដើម្បីធានាសុវត្ថិភាពសិស្សដែលស្របតាមបទប្បញ្ញត្តិដែលពាក់ព័ន្ធនៃច្បាប់រដ្ឋ និងច្បាប់ប្រទេស។
- ❑ សេវាកម្ម ឬប្រតិបត្តិការរដ្ឋបាលដែលអាចត្រូវបានផ្តល់ជូនពីចម្ងាយ (ឧទាហរណ៍ ការចុះឈ្មោះក្នុងថ្នាក់ ការដាក់បញ្ជូនបែបបទឬឯកសារ ។ល។) ត្រូវបានផ្លាស់ប្តូរទៅជាអនឡាញ។

**វិធានការណ៍បន្ថែមទាំងឡាយណាដែលមិនបានរាប់បញ្ចូលខាងលើ គួរត្រូវបានដាក់បង្ហាញនៅលើទំព័រដាច់ដោយឡែក ដែលអ្នកពាក់ព័ន្ធគួរភ្ជាប់ជាមួយឯកសារនេះ។**

**លោក-អ្នកអាចទាក់ទងមកបុគ្គលិកយើងខ្ញុំដូចខាងក្រោម ប្រសិនបើមានសំណួរ ឬមតិយោបល់អំពីពិធីការនេះ៖**

**ឈ្មោះទំនាក់ទំនងនៃកិច្ចការ៖** ______________________________

**លេខទូរស័ព្ទ៖** ______________________________

**កាលបរិច្ឆេទកែសម្រួលចុងក្រោយ៖** ______________________________

## សេចក្តីសង្ខេបនៃនីតិវិធីចាំបាច់ដែលមាននៅក្នុងឯកសារនេះ

- ❑ សាលារៀនត្រូវតែមានផែនការទប់ស្កាត់ ឆ្លើយតប និងគ្រប់គ្រងជំងឺ COVID-19 (COVID-19 Containment, Response and Control Plan) ដែលពិពណ៌នាអំពីវិធីសាស្ត្រដ៏ទូលំទូលាយរបស់សាលារៀនដើម្បីទប់ស្កាត់ និងគ្រប់គ្រងការរីករាលដាលនៃជំងឺ COVID-19 នៅក្នុងបរិវេណសាលារៀន។
- ❑ ផែនការ ឬពិធីការមួយដើម្បីចាប់ផ្តើម ផែនការគ្រប់គ្រងការប៉ះពាល់ទៅនឹងមេរោគនៅសាលារៀន ដែលស្របទៅតាមការណែនាំរបស់នាយកដ្ឋានសុខភាពសាធារណៈ (DPH)។
- ❑ ផែនការមួយដើម្បីរាយការណ៍អំពីករណីដែលមានជាក្រុម (3 ករណីឡើងទៅក្នុងអំឡុងពេល 14 ថ្ងៃ) ទៅកាន់នាយកដ្ឋានសុខភាពសាធារណៈជាបន្ទាន់។
- ❑ ផែនការ ឬពិធីការមួយសម្រាប់បញ្ចូលការធ្វើតេស្តរកមេរោគ COVID-19 ទៅក្នុងប្រតិបត្តិការជម្មតារបស់សាលារៀន ដែលយ៉ាងហោចណាស់គួរតែរៀបរាប់អំពីវិធីសាស្ត្រដើម្បីធានាការចូលធ្វើតេស្តសម្រាប់សិស្ស ឬបុគ្គលិកដែលមានរោគសញ្ញា ឬបានស្គាល់ឬសង្ស័យថា មានការប៉ះពាល់ទៅនឹងបុគ្គលដែលផ្ទុកមេរោគ SARS-CoV-2។
- ❑ ផែនការនេះត្រូវតែបញ្ជាក់ថារាល់លទ្ធផលតេស្តទាំងអស់នឹងត្រូវរាយការណ៍ទៅនាយកដ្ឋានសុខភាពសាធារណៈ។
- ❑ បុគ្គលិកទាំងអស់ត្រូវបានណែនាំថាកុំឱ្យមកធ្វើការ ប្រសិនបើមានជំងឺ ឬប្រសិនបើពួកគេបានប៉ះពាល់ទៅនឹងមនុស្សដែលមានមេរោគជំងឺ COVID-19។
- ❑ កន្លែងការងារត្រូវបានតម្រូវចាំបាច់ឱ្យផ្តល់ជូនម៉ាស់កម្រិតវេជ្ជសាស្ត្រ និងឧបករណ៍ជំនួយការដកដង្ហើមដែលបិទជិតល្អ ទៅដល់បុគ្គលិកនៅសាលារៀនដោយមិនគិតថ្លៃពីបុគ្គលិកសាលារៀនរបស់ពួកគេ  ដែលធ្វើការនៅខាងក្នុងអគារ និងមានទំនាក់ទំនងឬការប៉ះពាល់ជាមួយនឹងអ្នកដទៃ សម្រាប់ការប្រើប្រាស់ដោយស្ម័គ្រចិត្ត។
- ❑ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានចែកចាយទៅដល់បុគ្គលិកទាំងអស់។
- ❑ ព័ត៌មានគួរត្រូវបានផ្ញើទៅកាន់ឪពុកម្តាយនិងសិស្ស មុនពេលសាលារៀនចាប់ផ្តើម ពាក់ព័ន្ធនឹងគោលការណ៍សាលារៀនដែលទាក់ទងនឹងការទប់ស្កាត់ជំងឺ COVID-19។
- ❑ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានបិទផ្សាយនៅគ្រប់ច្រកចូលសាធារណៈទៅសាលារៀន ហើយបង្ហោះក្នុងទំព័រមុខសម្រាប់សាធារណៈនៅតាមគេហទំព័រសាលារៀន ឬតំបន់។
- ❑ ស្លាកសញ្ញាត្រូវបានបិទផ្សាយនៅច្រកចូលសាធារណៈនីមួយៗរបស់សាលារៀនដែលរំលឹកដល់ភ្ញៀវថា ពួកគេមិនគួរចូលក្នុងទីកន្លែងឡើយ ប្រសិនបើពួកគេមានរោគសញ្ញានៃជំងឺ COVID-19។
- ❑ គម្រោងមួយសម្រាប់ការធ្វើបច្ចុប្បន្នកម្មទៅលើផែនការអប់រំលក្ខណៈបុគ្គល (IEPs) និងផែនការ 504 របស់សិស្សដែលមានតម្រូវការពិសេស ត្រូវបានបង្កើតឡើងដើម្បីធានាបានថា ការអប់រំអាចបន្តទៅបានដោយមិនប្រឈមនឹងហានិភ័យហួសហេតុដល់សិស្ស។
- ❑ យោងតាមសេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាលសាធារណៈរបស់រដ្ឋ បុគ្គលិកសាលារៀនទាំងអស់ត្រូវបង្ហាញភ័ស្តុតាងនៃការចាក់ថ្នាំបង្ការជំងឺ COVID-19 ពេញលេញ ឬធ្វើតេស្តរកមេរោគយ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍។